# កម្រងឯកសារ

## គម្រោងអប់រំគ្រូវិទ្យាសាស្ត្រ

ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន

កម្មវិធីបំប៉នលើកទី៣ សម្រាប់នាយកសាលា និង
គ្រូឧទ្ទេសវិទ្យាសាស្ត្រមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ







២៧ កញ្ញា ដល់ ០២ តុលា ២០១០

រៀបចំដោយ
ក្រុមការងារគម្រោង STEPSAM2

# គណៈកម្មការនិពន្ធ

## គណៈកម្មការនិពន្ធ
## មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ

**រូបវិទ្យា**

លោកស្រី ខែក សំណាង

លោក ម៉ែន វណ្ណារី

**គីមី**

លោក សិត សេង

លោក ស្រី ប៊ុន ជៀនស៊ីផល

**ជីវវិទ្យា**

លោក ម៉ម ចាន់សៀន

កញ្ញា ប៊ុន សុផានី

លោកស្រី ហួ ឃីម

**ផែនដីវិទ្យា**

លោកស្រី ណារ៉េត ប៉ូលីវីន

កញ្ញា គឹម បូរីផល

គ្រូឧទ្ទេសវិទ្យាសាស្ត្រ

មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ

## គណៈកម្មការត្រួតពិនិត្យ

លោក សិត សេង

លោក ម៉ម ចាន់សៀន

លោក ដោ ប៉េងឡុង

## គណៈកម្មការរៀបរៀង និងចងក្រង

លោក ស្រី រតនៈ

# អារម្ភកថា

លោកគ្រូ–អ្នកគ្រូ និងប្រិយ៍មិត្តអ្នកអានទាំងអស់ជាទីមេត្រី កម្រងឯកសារដែលលោកគ្រូ –អ្នកគ្រូនិងប្រិយ៍មិត្តអ្នកអាន កំពុងកាន់នៅនឹងដៃនេះ គឺជាឯកសារដែលចងក្រងបានពីវគ្គបំប៉នគ្រូឧទ្ទេសវិទ្យាសាស្ត្រនៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគទាំង៦នៅទូទាំងប្រទេស។ វគ្គបំប៉ននេះបានធ្វើនៅវិទ្យាស្ថានជាតិអប់រំពីថ្ងៃទី **២៧ កញ្ញា ដល់ថ្ងៃទី 0២ តុលា ឆ្នាំ ២០១០** ក្រោមកិច្ចសហប្រតិបត្តិការរបស់ក្រសួងអប់រំយុវជន និងកីឡា និងគម្រោងអប់រំគ្រូវិទ្យាសាស្ត្រ (STEPSAM2)ក្នុងគោលបំណងពង្រឹងសមត្ថភាពគ្រូឧទ្ទេសបន្ថែមទៀតលើផ្នែកវិទ្យាសាស្ត្របង្រៀន និងរៀនដោយផ្អែកលើការរិះរក , ការសិក្សាស្រាវជ្រាវមេរៀន និងជំនាញក្នុងការសង្កេតថ្នាក់ ។

ដើម្បីជាជំនួយដល់ការសិក្សាស្រាវជ្រាវរបស់លោកគ្រូ –អ្នកគ្រូ និងប្រិយ៍មិត្ត អ្នកអានទាំងអស់ ក្រុមការងារយើងខ្ញុំបានប្រមូលនូវរាល់ឯកសារទាំងអស់ដែលបានប្រើក្នុងវគ្គបំប៉ន សម្រាប់គ្រូ សាលាគរុកោសល្យទាំងអស់មកចងក្រងជាសៀវភៅនេះឡើង។ កម្រងឯកសារនៅក្នុងសៀវភៅនេះ គឺ ជាទន់សម្រាប់ជួយលោកគ្រូ–អ្នកគ្រូអោយអាចកែលម្អការបង្រៀនរបស់ខ្លួនឆ្ពោះទៅរកការបង្រៀន និងរៀនផ្អែកលើការរិះរក ដែលផ្តោតទៅលើការគិតរបស់សិស្សជាចម្បង។ នៅក្នុងកម្រងឯកសារនេះដែរ មានបង្ហាញពីរបៀបរៀបចំឯកសារមួយចំនួន ដើម្បីឲ្យការបង្រៀនរបស់លោកគ្រូ –អ្នកគ្រូមានសកម្មភាពល្អ ដូចជា កិច្ចតែងការបង្រៀន សន្លឹកកិច្ចការ ប្លង់ក្តារខៀន និងកំណត់សម្គាល់មេរៀនជាដើម។

ក្រុមការងារយើងខ្ញុំ សូមអធ្យាស្រ័យនូវរាល់ចំណុចខ្វះខាតទាំងឡាយដែលអាចកើតមានដោយយថាហេតុ ទាំងខ្លឹមសារ និងបច្ចេកទេសក្នុងការចងក្រងឯកសារនេះ។

ក្រុមការងារយើងខ្ញុំ រងចាំទទួលការរិះគន់កែលម្អពីសំណាក់លោកគ្រូ–អ្នកគ្រូ និងប្រិយ៍មិត្តអ្នកអានទាំងអស់ ដើម្បីធ្វើឲ្យកម្រងឯកសារនេះកាន់តែមានសារប្រយោជន៍ដល់ការលើកកម្ពស់ការបង្រៀន និងរៀនថែមទៀត។

**គ្រូឧទ្ទេសថ្នាក់ជាតិ**

**និង**

**ក្រុមការងារគម្រោងអប់រំគ្រូវិទ្យាសាស្ត្រ (STEPSAM2)**

# មាតិកា

គណៈកម្មការនិពន្ធ .................................................... i
អារម្ភកថា .................................................... ii
មាតិកា .................................................... iii

១. កិច្ចតែងការបង្រៀន ផ្អែកលើការរិះរក របស់គ្រូឧទ្ទេសគម្រោង STEPSAM2

១.១. រូបវិទ្យា

១.១.១. បាតុភូតរេស្វូណង់ រេស្វូណង់ស្វរ និងប្រអប់រេស្វូណង់ និងឧបករណ៍ភ្លេង .................... 1

១.១.២. សៀគ្វីអគ្គីសនី .................................................... 6

១.២. គីមី

១.២.១. បាតុភូតកត្តាមានឥទ្ធិពលលើល្បឿននៃការរលាយរបស់អង្គធាតុរលាយក្នុងទឹក .................... 11

១.២.២. ការកំណត់បរិមាណឧស្ម័នអុកស៊ីសែនក្នុងខ្យល់ .................................................... 15

១.៣. ជីវវិទ្យា

១.៣.១. ប្រព័ន្ធដំណឹកនាំរុក្ខជាតិ .................................................... 21

១.៣.២. ការរំលាយអាហារក្នុងពោះវៀនតូច .................................................... 28

១.៣.៣. អូស្មូស .................................................... 33

១.៤. ផែនដីវិទ្យា

១.៤.១. បរិយាកាស .................................................... 39

១.៤.២. ទិសខ្យល់បក់ .................................................... 44

២. កិច្ចតែងការបង្រៀនគម្រូ នៅតាមមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ
២.១. រូបវិទ្យា (ចំណាំងបែរនៃពន្លឺ)......53
២.២. រូបវិទ្យា (ការចម្លងកម្ដៅ)......60
២.៣. គីមី (អត្តសញ្ញាណកម្មអាស៊ីត បាស និងណឹតក្នុងសូលុយស្យុងមួយចំនួន)......67
២ .៤.គីមី (ការកំណត់ប្រភេទតម្រុង)......73
២.៥. ជីវវិទ្យា(ការងារអនុវត្តន៍ បរិមាណស្តូម៉ាត)......79
២.៦. ជីវវិទ្យា(ការជក់បារីដោយប្រយោល)......87
២.៧. ផែនដីវិទ្យា(សំណើមអាកាស)......94
២.៨. ផែនដីវិទ្យា(ទឹកជាធាតុរំលាយ)......101
៣. ផែនការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន នៅក្នុង មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ
៣.១. ភ្នំពេញ......109
៣.២. កណ្ដាល......112
៣.៣. កំពង់ចាម......115
៣ .៤.បាត់ដំបង......118
៣.៥. តាកែវ......121
៣.៦. ព្រៃវែង (ជីវវិទ្យា និងផែនដីវិទ្យា)......125
៣.៧. ព្រៃវែង (រូបវិទ្យា និងគីមី)......128

# ១.

# កិច្ចតែងការបង្រៀន ផ្ដែកលើការរិះរក

# របស់

# គ្រូឧទ្ទេសគម្រោង

# STEPSAM2

# ១.១.រូបវិទ្យា

# កិច្ចតែងការបង្រៀន

១/ មេរៀន: ស្ប៊ិចសូរ (រលកសូរ)
២/ ទីតាំងរបស់មេរៀន: ជំពូកទី២ មេរៀនទី២ សៀវភៅថ្នាក់ទី១០ (កម្មវិធីសិក្សាចាស់)
មេរៀនមុន: ធម្មជាតិលំញ័រនៃសូរ
មេរៀនបន្ទាប់: សូរអ៊ុលត្រា
៣/ ប្លង់មេរៀន:

1) មេរៀនទី១៖ ធម្មជាតិលំញ័រនៃសូរ

សិស្សនឹងរៀនពីការបង្កើតសូរ ដំណាលសូរ-សូរខ្វះ និងទំនួលសូរ។

2) មេរៀនទី២៖ ស្ប៊ិចសូរ
   ១. អាំងតង់ស៊ីតេសូរ
   ២. កំពស់សូរ  (មេរៀនថ្ងៃនេះ)
   ៣. ស្ប៊ិចសូរ
   ៤. សូរ និងសូររំខាន
3) មេរៀនទី៣៖ សូរអ៊ុលត្រា

សិស្សនឹងរៀនពីសូរអ៊ុលត្រា ដំនាលសូរអ៊ុលត្រា លក្ខណៈនៃសូរអ៊ុលត្រា និងអនុវត្ត។

4/ មេរៀនទី៤៖ សូរ និងតន្ត្រី (រយៈពេល: ៥០នាទី)

សិស្សនឹងរៀនពីបាតុភូតរេសូណង់ រេសូណង់សូរ និងប្រអប់រេសូណង់ និងឧបករណ៍ភ្លេង។

I- វត្ថុបំណងមេរៀន:

- ពិពណ៌នាពីកំពស់សូរដោយប្រៀបធៀបសូរឆ្មារ និងសូរគ្រាវដោយប្រើប្រាស់អូស៊ីយ៉ូស្កុប និងអូស៊ីលេទ័រ។
- មានជំនាញក្នុងការប្រើប្រាស់អូស៊ីយ៉ូស្កុប និងអូស៊ីលេទ័រ។
- មានបំរុងប្រយ័ត្នក្នុងការប្រើប្រាស់អូស៊ីយ៉ូស្កុបជាមួយប្រភព ២២០v រឺ ១០០v

II- សម្ភារៈបង្រៀន: អូស៊ីយ៉ូស្កុប អូស៊ីលេទ័រ មីក្រូផូន ឧបករណ៍តន្ត្រី ហ្គីតា និងឃ្មោះ។
III- ខ្លឹមសារមេរៀន

| រយៈពេល | សកម្មភាពគ្រូ | ខ្លឹមសារ | សកម្មភាពសិស្ស |
|---|---|---|---|
| ជំហានទី១: លំនឹងថ្នាក់ | | | |
| ២នាទី | ស្វាគមន៍ | | |
| ជំហានទី២: រំលឹកមេរៀនចាស់ | | | |
| ៣នាទី | . ដូចម្តេចដែលហៅថាខួប?<br><br>. ដូចម្តេចដែលហៅថាប្រេកង់? | | . ខួបជារយៈពេលដែលចល័តប្រើដើម្បីធ្វើបានមួយលំយោលពេញ<br>. ប្រេកង់ជាចំនួនលំយោលពេញដែលធ្វើក្នុងមួយវិនាទី។ |

| ជំហានទី៣: មេរៀនថ្មី(៤០នាទី) | | | |
|---|---|---|---|
| ៥នាទី | មានឃ្មោះ២តូចមួយ និងធំមួយ នៅពេលគោះវា តើសូរទាំងពីរនេះខុសគ្នាដូចម្តេច? |  | . ខុសគ្នា: ឃ្មោះតូចមានសូរស្នារ និងឃ្មោះធំមានសូរគ្រាវ។ |
| | សូមមើលសំណួរគន្លឹះ: | តើអ្វីដែលកំណត់កំពស់សូរ? | |
| ១០នាទី | សំណួរនេះអ្នកទាំងអស់គ្នាពិបាកក្នុងការឆ្លើយ។ សូមឡើងមកមុខក្តារខៀន និងឈរជុំវិញអូស៊ីយ៉ូស្កុប ហើយសង្កេតមើលស៊ីញាល់របស់រលកដែលចេញពីសំលេងរបស់ខ្ញុំ។<br>. ចែកសិក្ខាកាមជា៤ក្រុម<br>. អោយគាត់ពិភាក្សាតាមក្រុមអំពីសំណួរគន្លឹះ។<br>. ក្រោយពីពិភាក្សាចប់ ក្រុមនីមួយៗឡើងឆ្លើយនូវចម្លើយស្មានទុក។<br>. សូមពន្យល់ពីហេតុផលនៃចម្លើយ | <br>. កំពស់សូរត្រូវបានកំណត់ដោយប្រេកង់។ | . សិក្ខាកាមទាំងអស់សង្កេត។<br>. ប្រេកង់<br>. ខួប<br>. ខួបវែង ខួបខ្លី<br>. ចំនួនរលកក្នុងពេលជំនាល។<br>. ដោយសារតែខួបវែង រលកមានប្រេកង់ទាប មានន័យថាសូរគ្រាវ។ ម្យ៉ាងវិញទៀត ខួបខ្លី រលកមាន ប្រេកង់ខ្ពស់ មានន័យថាសូរស្នារ។ |
| | សូមសិក្ខាកាមទាំងអស់សង្កេតមើលទំរង់របស់រលក | | |
| ២៥នាទី | . អោយសិក្ខាកាមអង្គុយជុំវិញអូស៊ីយ៉ូស្កុប។<br>. សូមស្តាប់យ៉ាងប្រុងប្រយ័ត្ននៅពេលដែលគោះឃ្មោះទាំងពីរ កេះហ្គីតាដែលមានខ្សែធំ និងតូច និងគោះកែវមានទឹក និងគ្មានទឹក តើមួយណាសូរស្នារ?<br>បញ្ជាក់ម្តងទៀតដោយបង្ហាញ |  | . សិក្ខាកាមសង្កេត<br>. ឃ្មោះតូចមានសូរស្នារ។<br>. ហ្គីតាមានខ្សែស្តើងបង្កើតសូរស្នារ។<br>. កែវគ្មានទឹក |

| | | | |
|---|---|---|---|
| | ទំរង់រលកលើអីស្វយ៉ីស្កូប។<br>. បន្ទាប់ពីសង្កេតចប់ ចែកសិក្ខាកាមជា៦ក្រុម ដើម្បីធ្វើការសន្និដ្ឋានតាមក្រុមនីមួយៗ និងសរសេរចូលក្នុងសន្លឹកកិច្ចការ<br>. ពិភាក្សាចប់ក្រុមនីមួយៗ សរសេរការសន្និដ្ឋានលើក្តារខៀន<br>. គ្រូធ្វើការសន្និដ្ឋានរួមដោយសរុបសេចក្តីសន្និដ្ឋានរបស់សិក្ខាកាម។<br>. គ្រូធ្វើពិសោធបញ្ជាក់ពីសេចក្តីសន្និដ្ឋានឡើងវិញដោយប្រើអូស៊ីយ៉ូស្កុប អូស៊ីលេទ័រ និងអូបាល័រ។ | . កំពស់ស្វរជាអ្នកកំណត់នូវប្រេកង់របស់រលកស្វរ។ | . ស្វរឆ្មារមានប្រេកង់ខ្ពស់ និងស្វរគ្រាវមានប្រេកង់ទាប។ ដូចនេះកំពស់ស្វរជាអ្នកកំណត់នូវប្រេកង់របស់រលកស្វរ។ |
| ជំហានទី៤: ពង្រឹងពុទ្ធិ | | | |
| ៣នាទី | . តើស្វរឆ្មារ និងស្វរគ្រាវមានភាពខុសគ្នាយ៉ាងដូចម្តេច? | | . ស្វរឆ្មារមានន័យថាមានប្រេកង់ខ្ពស់ និងស្វរគ្រាវមានប្រេកង់ទាប។ |
| ជំហានទី៥: បណ្តាំផ្ញើ | | | |
| ២នាទី | ពេលត្រឡប់ទៅផ្ទះវិញ សូមអានមេរៀនស្វរអុលត្រា ហើយជួបគ្នា ម៉ោងក្រោយ យើងនឹងរៀនពីមេរៀននេះ។ | | សិក្ខាកាមស្តាប់។ |

# សន្លឹកកច្ចការ

## រលកសូរ

១. សំណួរគន្លឹះ៖

| តើអ្វីដែលកំណត់កំពស់សូរ? |
|---|

២. សម្មតិកម្ម៖

៣. ពិសោធ៖

សម្ភារ:

អូស៊ីយ៉ូស្កុប អូសីលេទ័រ អូបាល័រ មីក្រូផូន ហ្គីតា ឃ្មោះ និងកែវពី។




៤. លទ្ធផល

ហ្គីតា ឃ្មោះ កែវ

៥. សន្និដ្ឋាន

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

# ប្លង់ក្តារខៀន

មេរៀនៈ រលកសូរ

លំនាំបញ្ហា៖



សំណួរគន្លឹះ៖

| តើអ្វីជាអ្នកកំណត់កំពស់សូរ? |
| --- |

សម្មតិកម្ម៖




ក្រុមទី១ ក្រុមទី២

ក្រុមទី៣ ក្រុមទី៤

លទ្ធផល៖ ក្រុមទី១ ក្រុមទី២

សន្និដ្ឋាន៖

សន្និដ្ឋានរួម៖

កំពស់សូរជាអ្នកកំណត់នូវប្រេកង់របស់រលកសូរ។

# កិច្ចតែងការបង្រៀន

មេរៀន: សៀគ្វីអគ្គិសនី

ថ្នាក់ទី 7:

រយៈពេល: 50នាទី

I. វត្ថុបំណង:

- បង្ហាញអំពីសៀគ្វីជាសេរី–តជាខ្នែង និងរបៀបវាស់អាំងតង់ស៊ីតេចរន្ត និងតង់ស្យុងបានត្រឹមត្រូវ តាមរយៈការ ពិសោធជាក់ស្តែង។
- ប្រៀបធៀបតម្លៃតង់ស្យុង និងអាំងតង់ស៊ីតេចរន្តក្នុងសៀគ្វីតសេរី និងសៀគ្វីតជាខ្នែង តាមរយៈលទ្ធផលពិសោធន៍បានត្រឹមត្រូវ។
- –មានបម្រុងប្រយ័ត្នក្នុងការប្រើប្រាស់វ៉ុលម៉ែត និងអំពែម៉ែ តដើម្បីវាស់តម្លៃអាំងតង់ស៊ីតេចរន្ត និងតង់ស្យុងក្នុងសៀគ្វី។

II.សម្ភារបង្រៀន:

–ថ្មពិល 3ដុំ, អំពូល3, ជើងទំរអំពូល, ជើងទំរថ្មពិល, អំពែម៉ែត, វ៉ុលម៉ែត, កុងតាក់។

III.ដំណើកនាំមេរៀន:

| សកកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| | ជំហានទី1<br>លំនឹងថ្នាក់ ស្វាគមន៍ | |
| . តើគេប្រើប្រាស់ឧបករណ៍អ្វីសំរាប់វាស់អាំងតង់ស៊ី ចរន្តអគ្គិសនី?<br>. តើគេត្រូវតវាដូចម្តេចនៅក្នុងសៀគ្វី?<br>. តើគេប្រើឧបករណ៍អ្វីសំរាប់វាស់តង់ស្យុងអគ្គិសនីក្នុងសៀគ្វី?<br>. តើគេតវាដូចម្តេចក្នុងសៀគ្វី?<br>. ឲ្យសិស្សឡើងគូរបបង្ហាញអំពីសៀគ្វីប្រើវ៉ុលម៉ែត និងសៀគ្វីប្រើអំពែម៉ែត។ | ជំហានទី2:រំលឹកមេរៀន<br>. គេប្រើប្រាស់អំពែម៉ែតសម្រាប់វាស់អាំងតង់ស៊ីតេចរន្ត។<br>. គេត្រូវតអំពែម៉ែតជាសេរីក្នុងសៀគ្វី<br>. គេប្រើវ៉ុលម៉ែតសម្រាប់វាស់តង់ស្យុងអគ្គិសនី។<br>. គេត្រូវតវាជាខ្នែងក្នុងកំណាត់សៀគ្វី។<br><br><br><br> | . សិស្សឆ្លើយ: គេប្រើអំពែម៉ែត<br><br>. សិស្សឆ្លើយ: គេតជាសេរី<br>ឆ្លើយ: គេប្រើវ៉ុលម៉ែត<br><br>សិស្សឆ្លើយ: គេតវាជាខ្នែង<br>. សិស្សឡើងគូរបលើក្តារខៀន |

<table>
<tr>
<td>គ្រូបង្ហាញសម្ភារៈ អំពូលខ្សែភ្លើង ថ្មពិល វ៉ុលម៉ែត អំពែម៉ែត.........។</td>
<td>ជំហានទី3: មេរៀនថ្មី<br>សៀគ្វីអគ្គិសនី</td>
<td>. សិស្សសង្កេត និងឆ្លើយនូវសំនួរ</td>
</tr>
<tr>
<td>. តើប្អូនណាអាចឆ្លើយនិងសំនួរនេះបាន?<br><br>. គ្រូបង្រៀនចែកឧបករណ៍ឲ្យសិស្សតាមក្រុមដើម្បីរៀបចំពិសោធន៍<br><u>ចំណាំ:</u> ចំពោះសៀគ្វីតជាខ្នែងត្រូវប្រើថ្មពិលពីរកូន និងសៀគ្វីតជាខ្នែងតថ្មពិល 3 កូនតជាសេរី។<br><br>. គ្រូឲ្យសិស្សបង្ហាញលទ្ធផល<br>. គ្រូបូកសរុបលទ្ធផលដែលទទួលបាន និងបង្ហាញ អំពីតម្លៃល្អៀងនៃលទ្ធផល</td>
<td>សំនួរគន្លឹះ៖ តើតម្លៃនៃអាំងតង់ស៊ីតេចរន្ត និងតម្លៃនៃតង់ស្យុងមានលក្ខណៈខុសគ្នា ដូចម្តេចនៅក្នុងសៀគ្វីតជាសេរី និង សៀគ្វីតជាខ្នែង?<hr>–ចំពោះសៀគ្វីតជាសេរី<br>. អាំងតង់ស៊ីតេថេរ<br>. តង់ស្យុងស្មើផលបូក<br>–ចំពោះសៀគ្វីតជាខ្នែង<br>. អាំងតង់ស៊ីតេស្មើផលបូក<br>. តង់ស្យុងថេរ<br><br>លទ្ធផលពិសោធ<br>+ចំពោះបង្គុំជាសេរី<br>$I = I_1 = I_2 = I_3$<br>$V = V_1 + V_2 + V_3$<br>+ចំពោះសៀគ្វីតជាខ្នែង<br>$I = I_1 + I_2 + I_3$<br>$V = V_1 = V_2 = V_3$<br>. បិទតារាងលទ្ធផល<br>. ការអានតម្លៃតាមរយៈឧបករណ៍<br>. តង់ស្យុងនៃថ្មពិល<br>. រេស៊ីស្តង់អំពូលមិនស្មើគ្នា</td>
<td>. សិស្សសង្កេត និងឆ្លើយសំណួរ<br><br>. សិស្សពិភាក្សាតាមក្រុមនីមួយៗ<br>. អាំងតង់ស៊ីតេស្មើគ្នាក្នុងសៀគ្វីតជាសេរី និងតជាខ្នែង។<br>ព្រោះអំពូលភ្លឺដូចគ្នា។<br><br>. សិស្សទទួលបានឧបករណ៍ពិសោធន៍ និងរៀបចំតាមក្រុម<br>. សិស្សបំពេញតារាង<br>+ចំពោះសៀគ្វី តជាសេរី<table><tr><td></td><td></td><td></td><td></td></tr><tr><td></td><td></td><td></td><td></td></tr></table>+ចំពោះសៀគ្វី តជាខ្នែង<table><tr><td></td><td></td><td></td><td></td></tr><tr><td></td><td></td><td></td><td></td></tr></table><br>. សិស្សឡើងបិទលទ្ធផលលើក្តារខៀន<br>. សិស្សស្តាប់នឹងកត់ត្រា</td>
</tr>
</table>

| | | |
|---|---|---|
| . គ្រូឲ្យសិស្សសន្និដ្ឋានតាមក្រុមនីមួយៗ<br><br>**គ្រូឲ្យសិស្សផ្ទៀងផ្ទាត់លទ្ធផលជាមួយសម្មតិកម្ម | សន្និដ្ឋាន:<br>+ចំពោះសៀគ្វីតជាសេរី<br>. អាំងតង់ស៊ីតេមានតម្លៃថេរ<br>. តង់ស្យុងស្មើ និងផលបូកតង់ស្យុងនៃសេរីនីមួយៗ<br>+ចំពោះសៀគ្វីតជាខ្នែង<br>. អាំងតង់ស៊ីតេ និងផលបូកអាំងតង់ស៊ីតេនៃខ្នែងនីមួយៗ។<br>. តង់ស្យុងមានតម្លៃថេរ | . សិស្សពិភាក្សានិងឡើងសរសេរលើក្ដារខៀន<br>+ចំពោះសៀគ្វី តជាសេរី<br>$I = I_1 = I_2 = I_3$<br>$V = V_1 + V_2 + V_3$<br>+ចំពោះសៀគ្វី តជាខ្នែង<br>$I = I_1 + I_2 + I_3$<br>$V = V_1 = V_2 = V_3$<br><br>. សិស្សផ្ទៀងផ្ទាត់ជាមួយសម្មតិកម្មដែលបានសរសេរក្នុងសន្លឹកកិច្ចការ |
| . តើឧបករណ៍អគ្គីសនីដែលប្រើនៅក្នុងផ្ទះគេតជាអ្វី?<br>. នៅក្នុងថ្មពិល និងវិទ្យុគេតថ្មពិលដូចម្ដេច? | ជំហានទី4 ពង្រឹងចំណេះដឹង<br>. ឧបករណ៍ប្រើប្រាស់ក្នុងផ្ទះគេច្រើនតជាខ្នែង។<br>. ក្នុងពិល និងវិទ្យុគេ តថ្មពិលជាសេរី។ | . ឧបករណ៍ប្រើក្នុងផ្ទះគេ តជាខ្នែងដូចជាឆ្នាំងអ៊ុត ,ទូរទស្សន៍,ចង្ក្រានអគ្គីសនី...។ |
| ចូរតម្លើងសៀគ្វីដូចរូប | ជំហានទី5 បណ្ដាំផ្ញើរ<br><br><br>V=…………………………..?<br><br><br>V=…………………………..? | . សិស្សកត់ត្រា និងយកទៅអនុវត្តនៅផ្ទះ |

# សន្លឹកកិច្ចការ

-លំនាំបញ្ហា: យើងបានសិក្សារួចហើយអំពីរបៀបវាស់អាំងតង់ស៊ីតេចរន្តដោយប្រើអំពែម៉ែត និងរបៀប វាស់តង់ស្យុងដោយ ប្រើវ៉ុលម៉ែតនៅក្នុងសៀគ្វី ។ ឥឡូវនេះចូរសង្កេតមើលការតម្លើងសៀគ្វីនេះ។

1-កំណត់បញ្ហា: តើតម្លៃអាំងតង់ស៊ីតេចរន្ត និងតម្លៃនៃតង់ស្យុងមានភាពខុសគ្នាដូចម្តេចនៅក្នុងសៀគ្វីតជាសេរី និងតជាខ្នែង?

2-សម្មតិកម្ម:

-

-

-

-

3-ពិសោធន៍:

ក-សម្ភារៈ ថ្មពិល ៣កូន, អំពូល៣, វ៉ុលម៉ែត១, អំពែម៉ែត១ , ទំរថ្មពិល, កុងតាក់, ជើងអំពូល។

ខ-ដំណើរការពិសោធន៍: តម្លើងសៀគ្វីដែលតជាខ្នែង និងតជាសេរី រួចវាស់អាំងតង់ស៊ីតេចរន្ត I និងតង់ស្យុងV។

***ចំពោះសៀគ្វីតជាខ្នែងត្រូវប្រើថ្មពិលពីរកូនតជាសេរី និងសៀគ្វីតជាសេរីត្រូវប្រើថ្មពិលបីតជាសេរី ។

4-លទ្ធផល:

+សៀគ្វីតជាសេរី

| | | | |
|---|---|---|---|
| V= | $V_1$= | $V_2$= | $V_3$= |
| I= | $I_1$= | $I_2$= | $I_3$= |

V= ---------------------------------------- ?

I= ---------------------------------------- ?

+សៀគ្វីតជាខ្នែង

| | | | |
|---|---|---|---|
| V= | $V_1$= | $V_2$= | $V_3$= |
| I= | $I_1$= | $I_2$= | $I_3$= |

V= ---------------------------------------- ?

I= ---------------------------------------- ?

5-សន្និដ្ឋាន:

## ប្លង់ភ្ជារខៀន

-ឲ្យសិស្សឡើងគូរូប:







-សំនួរគន្លឹះ  តើតម្លៃនៃអាំងតង់ស៊ីតេចរន្ត និងតម្លៃនៃតង់ស្យុងមានភាពខុសគ្នាដូចម្តេចនៅក្នុងសៀគ្វីតជាសេរី និងសៀគ្វីតជាខ្នែង

-សម្មតិកម្ម:

+ចំពោះសៀគ្វីតជាសេរី

. អាំងតង់ស៊ីតេមានតម្លៃថេរ

. តង់ស្យុងស្មើ និងផលបូក

+ចំពោះសៀគ្វីតជាខ្នែង

. អាំងតង់ស៊ីតេស្មើ និងមានផលបូក

. តង់ស្យុងមានតម្លៃថេរ

-លទ្ធផល

-សន្និដ្ឋាន:

+ចំពោះសៀគ្វីតជាសេរី

$I = I_1 = I_2 = I_3$

$V = V_1 + V_2 + V_3$

+ចំពោះសៀគ្វីតជាខ្នែង

$I = I_1 + I_2 + I_3$

$V = V_1 = V_2 = V_3$

-ការអនុវត្តក្នុងជីវភាពរស់នៅ:

-ឧបករណ៍អគ្គិសនីដែលប្រើប្រាស់នៅក្នុងផ្ទះគេតជាខ្នែង ។

-នៅក្នុងពិល ឬវិទ្យុគេប្រើថ្មពិលផ្គុំជាសេរី

# ១.២. គីមី

# កិច្ចតែងការបង្រៀន

**ថ្នាក់ទី៩**

**ជំពូកទី២៖** ទឹក និងសូលុយស្យុង **មេរៀនទី៣៖** សូលុយស្យុង

**ប្រធានបទ៖** កត្តាមានឥទ្ធិពលលើល្បឿននៃការរលាយរបស់អង្គធាតុរលាយក្នុងទឹក

**រយៈពេល៖** ៥០ នាទី

I– **វត្ថុបំណង៖**

- រៀបរាប់ពីកត្តាផ្សេងៗដែលមានឥទ្ធិពលលើការរលាយរបស់អំបិលក្នុងទឹកសមស្របតាមលទ្ធផលពិសោធន៍
- រិះគិត និងធ្វើពិសោធន៍យ៉ាងសកម្ម ដើម្បីកំណត់កត្តាដែលធ្វើឲ្យអំបិលអាចរលាយក្នុងទឹកបានលឿនតាមរយៈសកម្មភាពក្រុម
- ពង្រីកចំណាប់អារម្មណ៍សិស្សបន្ថែមទៀត ក្នុងការសង្កេតបាតុភូតវិទ្យាសាស្ត្រតាមរយៈសំណួរបំផុស និងការពិសោធ

II– **សម្ភារ៖** អំបិលគ្រួស(NaCl), ទឹកបរិសុទ្ធ, កែវជ័រថ្លា, ចង្កឹះកូរ, ញញួរ, នាឡិកាក្រិត ឬនាឡិកាដៃ (បើមាន)

III– **ដំណើរការមេរៀន**

| សកម្មភាពគ្រូ | ខ្លឹមសារ | សកម្មភាពសិស្ស | វាយតម្លៃ |
|---|---|---|---|
| គ្រូតពិនិត្យវិន័យ អនាម័យ សណ្តាប់ធ្នាប់ វត្តមាន………. | **ជំហានទី១៖ លំនឹងថ្នាក់** (2 min) | សិស្សអង្គុយតាមក្រុមយ៉ាងរៀបរយ | សិស្សត្រៀមខ្លួនជាស្រេចសម្រាប់ដំណើរការរៀន |
| – អ្វីទៅជាសូលុយស្យុង<br><br>– ឲ្យសិស្សលើកឧ.នៃសូលុយស្យុងដែលមានក្នុងជីវភាពប្រចាំថ្ងៃ | **ជំហានទី២៖ រំឭកមេរៀន** (3 min)<br>អំពីសូលុយស្យុង | – សូលុយស្យុងជាល្បាយស្មើសាច់ នៃអង្គធាតុរលាយ និងអង្គធាតុរំលាយ ហើយដែលមិនអាចញែកបានដោយវិធីច្រោះ<br>– ទឹកអំបិល ទឹកត្រី ទឹកខ្មេះ……… | សិស្សអាចឆ្លើយសំណួររំឭកបានត្រឹមត្រូវ |

| | | | |
|---|---|---|---|
| – តើយើងអាចបង្កើតសូលុយស្យុងទឹកអំបិលយ៉ាងដូចម្តេច?<br>– ឲ្យសិស្សស្ម័គ្រចិត្តពីរនាក់ឡើងមកខាងមុខ និងធ្វើការប្រកួតរំលាយអំបិលក្នុងទឹក តើអ្នកណាអាចធ្វើឲ្យអំបិលឆាប់រលាយក្នុងទឹកអស់មុន?<br>– ហេតុអ្វីបានជាគាត់អាចរំលាយអំបិលអស់មុនគេ? | **ជំហានទី៣៖ មេរៀនថ្មី** (40 min)<br>កត្តាមានឥទ្ធិពលលើការរលាយរបស់អង្គធាតុរំលាយក្នុងសូលុយស្យុង<br><br>**ការប្រកួតរំលាយអំបិល(អំបិលគ្រួស) ក្នុងទឹក** (5 min) | – ដាក់អំបិលចូលក្នុងទឹក រួចកូរឲ្យរលាយ<br><br>– សិស្សពីរនាក់ប្រកួតគ្នា ដើម្បីរំលាយអំបិលក្នុងទឹក សិស្សផ្សេងទៀតជាអ្នកសង្កេត និងធ្វើជាសាក្សី ក្នុងការកាត់សេចក្តីឈ្នះចាញ់ (អ្នកឈ្នះនឹងទទួលបានរង្វាន់ស្កគ្រាប់????)<br>– ពីព្រោះគាត់កូរលឿនជាង ... | សិស្សរីករាយ និងចូលរួមក្នុងការប្រកួតរំលាយអំបិលក្នុងទឹក |
| **សំណួរគន្លឹះ. ចូរគិតទាំងអស់គ្នា ថាធ្វើដូចម្តេចខ្លះដើម្បីរំលាយអំបិលក្នុងទឹកឲ្យរលាយបានលឿន? តើអ្នកអាចរកបានប៉ុន្មានវិធី?** | | | |
| – ឲ្យសិស្សពិភាក្សាតាមក្រុម និងផ្តល់យោបល់ទៅលើសំណួរគន្លឹះ | **សម្មតិកម្ម** (5 min)<br>គំនិតទាំងនោះអាចទាក់ទងទៅនឹង៖ ការកូរ សីតុណ្ហភាព និងផ្ទៃប៉ះរបស់អង្គធាតុរលាយ | – ពិភាក្សាតាមក្រុម និងផ្តល់យោបល់អាជា៖<br>• ប្រសិនបើកូរ អំបិលឆាប់រលាយ<br>• ប្រសិនបើសី. ទឹកក្តៅ អំបិលឆាប់រលាយ<br>• ប្រសិនបើអំបិលម៉ត់ នោះវាឆាប់រលាយ... | សហការ និងពិភាក្សាតាមក្រុម ព្រមទាំងផ្តល់យោបល់យ៉ាងផុសផុល។ |
| – សូមគិតថា តើត្រូវបញ្ជាក់គំនិតរបស់អ្នកយ៉ាងដូចម្តេច?<br>*<u>គ្រូអាចកែលម្អ ឬបន្ថែមគំនិតដើម្បីតម្រង់គំនិតសិស្សទៅរកដំណើរការពិសោធសមស្រប</u>* | **ការរៀបចំប្លង់ពិសោធន៍** (5 min) | – គូសប្លង់ពិសោធន៍ក្នុងសន្លឹកកិច្ចការ រួចឡើងបង្ហាញតាមក្រុម | ពិភាក្សាតាមក្រុមដើម្បីរៀបចំប្លង់ពិសោធន៍យ៉ាងសកម្ម |

| | | | |
|---|---|---|---|
| – ចូរធ្វើពិសោធន៍បញ្ជាក់គំនិតរបស់អ្នក! *<u>ដើម្បីចំណេញពេល គ្រូរៀបចំឲ្យសិស្ស១ក្រុមធ្វើពិសោធន៍លើកត្តា១ តែត្រូវជំរុញ ឬទុកពេលឲ្យសិស្សមានឱកាស ពិភាក្សាគ្នាបានច្រើន។</u>* | **ការសង្កេតពិសោធន៍** (10 min) | – សិស្សធ្វើពិសោធន៍តាមក្រុម និងបំពេញសន្លឹកកិច្ចការ | ធ្វើពិសោធន៍ និងសង្កេតបានត្រឹមត្រូវ |
| – រៀបចំឲ្យសិស្សតាមក្រុមធ្វើបទបង្ហាញអំពីលទ្ធផលពិសោធន៍របស់គេ *<u>គ្រូជំរុញការពិភាក្សារបស់សិស្ស ឲ្យកាន់តែស៊ីជម្រៅ ជាពិសេសលើវិធីសង្កេត និងការកំណត់កត្តាថេរ កត្តាត្រូវសង្កេតវាស់វែង ជាដើម។</u>* | **ការបង្ហាញលទ្ធផលពិសោធន៍** (15 min) | – សិស្សបង្ហាញលទ្ធផលពិសោធន៍តាមក្រុមដល់ក្រុមដទៃទៀត និងធ្វើការពិភាក្សា | ក្រុមនីមួយៗបង្ហាញលទ្ធផលពិសោធន៍របស់គេយ៉ាងសកម្ម |
| – តើថ្ងៃនេះ ប្អូនបានរកឃើញកត្តាអ្វីខ្លះ ដែលអាចធ្វើឲ្យអំបិលរលាយក្នុងទឹកបានកាន់តែលឿន? | **ជំហានទី៤៖ ពង្រឹងចំណេះដឹង** (2 min) | – កត្តាទាំងនោះមាន៖ បង្កើនការកូរ បង្កើនសី . និងដំអំបិលឲ្យម៉ត់ | សិស្សអាចឆ្លើយសំណួរបានត្រឹមត្រូវ |
| – ផ្តល់កិច្ចការផ្ទះឲ្យសិស្សធ្វើនៅផ្ទះ ហើយប្រាប់ពួកគេថា នៅថ្ងៃក្រោយយើងនឹងធ្វើការពិសោធជាក់ស្តែង ទៅតាមគំនិតក្រុមនីមួយៗ | **ជំហានទី៥៖កិច្ចការផ្ទះ** (3 min) *ប្អូនបានដឹងរួចមកហើយអំពីកត្តាដែលធ្វើឲ្យអង្គធាតុរលាយ(អំបិល)រលាយក្នុងទឹកកាន់តែលឿន។ ប៉ុន្តែ ឧបមាថាអ្នកមានអង្គធាតុរលាយជាច្រើនដូចជា អំបិល ស្ករ ប៊ីចេង... តើអ្នកត្រូវធ្វើដូចម្តេចដើម្បីដឹងថាអង្គធាតុរលាយមួយណារលាយក្នុងទឹកបានច្រើនជាងគេ? សូមគិតពីប្លង់ពិសោធន៍...* | – កត់ត្រាកិច្ចការផ្ទះចូលក្នុងសៀវភៅ | កត់ត្រាកិច្ចការផ្ទះចូលក្នុងសៀវភៅ |

## ***សន្លឹកកិច្ចការសិស្ស***

**កត្តាមានឥទ្ធិពលលើល្បឿននៃការរលាយរបស់អង្គធាតុរលាយក្នុងទឹក**

**ការសង្កេត៖** ចូរសង្កេតមើលសិស្សពីរនាក់រំលាយអំបិលចូលក្នុងទឹក តើអ្នកណារំលាយអំបិលបានអស់មុន? ហេតុអ្វី?

……………………………………………………………………………………………

……………………………………………………………………………………………

**សំណួរគន្លឹះ៖**

| |
|---|
| |

**សម្មតិកម្ម៖**

……………………………………………………………………………………………

……………………………………………………………………………………………

……………………………………………………………………………………………

**ចូររៀបចំប្លង់ពិសោធន៍**

| |
|---|
| |

Let confirm your ideas!!!

(((((((ចូរធ្វើពិសោធន៍បញ្ជាក់គំនិតរបស់អ្នក)))))))

**លទ្ធផលពិសោធន៍៖** សូមសរសេរអ្វីដែលអ្នកសង្កេតឃើញ ចូលក្នុងតារាងខាងក្រោម រួមទាំងរយៈពេលដែលធ្វើឲ្យអំបិលរលាយអស់ទាំងស្រុងក្នុងទឹក។

| កត្តា | ការសង្កេត និងរយៈពេលរលាយរបស់អំបិល |
|---|---|
| *ទី១៖*………………………… | |
| *ទី២៖*………………………… | |
| *ទី៣៖*………………………… | |

**ពិភាក្សា**

1. តើអ្នកបានរកឃើញអ្វីខ្លះ តាមរយៈការសង្កេតរបស់អ្នក?

……………………………………………………………………………………………

……………………………………………………………………………………………

2. ដើម្បីឲ្យលទ្ធផលរបស់អ្នកកាន់តែមានន័យ និងជឿជាក់បាន តើអ្នកត្រូវធ្វើការប្រៀបធៀបយ៉ាងដូចម្ដេច?

……………………………………………………………………………………………

……………………………………………………………………………………………

……………………………………………………………………………………………

# កិច្ចតែងការបង្រៀន

មេរៀន សមាសភាពខ្យល់

ប្រធានបទ ការកំណត់បរិមាណឧស្ម័នអុកស៊ីសែនក្នុងខ្យល់ រយៈពេល ១ម៉ោង សំរាប់ថ្នាក់ទី៧ថ្មី

ប្លង់ខ្លឹមសារមេរៀន
មេរៀនមុន ៖ ទំនាក់ទំនងរវាងរយៈពេលចំហេះ និងមាឌខ្យល់
មេរៀនត្រូវបង្រៀនៈ សមាសភាពខ្យល់

ប្រធានបទ ការកំណត់បរិមាណឧស្ម័នអុកស៊ីសែនក្នុងខ្យល់
មេរៀនបន្ទាប់៖ លក្ខណៈសំគាល់ឧស្ម័នក្នុងខ្យល់ និងទំនាក់ទំនងភាវរស និងខ្យល់
១.វត្ថុបំណង៖

ក្រោយពីបានសិក្សាមេរៀនម៉ោងនេះចប់សិស្សអាច ៖

- ពណ៌នាពី សមាសភាពផ្សំក្នុងខ្យល់ តាមរយៈការសង្កេតពិសោធន៍បង្ហាញរបស់គ្រូបានត្រឹមត្រូវ ។
- កំណត់របៀបវាស់មាឌ និងបរិមាណជាភាគរយនៃឧស្ម័នអុកស៊ីសែនក្នុងខ្យល់តាមរយៈការអនុវត្តពិសោធន៍ដោយសិស្សផ្ទាល់បានត្រឹមត្រូវ។
- បង្កើនគំនិតសហការគ្នាជាក្រុម និងមានបំរុងប្រយ័ត្នក្នុងពេលពិសោធ។

២. សម្ភារៈ កែវធំ កែវតូច សីរ៉ាំង ៥០មល កូនកន្ត្រៃ ស្កុតមុខពីរ ទូយោជ័រ ដង្កៀបចាប់ ទៀន ឈើគូស ចានក្លាំជ័រថ្លា ឃ្នៀប ហ្វឺត និង ទឹក ។

៣. ដំណឹកនាំមេរៀន៖

| សកម្មភាពគ្រូ | ខ្លឹមសារ | សកម្មភាពសិស្ស |
|---|---|---|
| គ្រប់គ្រងថ្នាក់រៀន | ជំហានទី១ (២នាទី )<br>រៀបចំថ្នាក់រៀន និងអវត្តមានសិស្ស | រក្សាការស្ងាត់ស្ងៀម អវត្តមាន |

| | | |
|---|---|---|
| . ចំហេះជាអ្វី?<br>. ហេតុអ្វីបានជាយើងដឹងថាល្ងើយ?<br>. ហេតុអ្វីបានជាយើងដឹងថាស្លឹកឈើរង្គើ?<br>. តើខ្យល់មានលក្ខណៈរូបសំគាល់ដូចម្ដេចខ្លះ? | ជំហានទី២ (២នាទី )<br>ចំហេះ និង លក្ខណៈនៃខ្យល់ | . ចំហេះជាការរបស់អង្គធាតុមួយជាមួយអុកស៊ីសែននៃខ្យល់ ។<br>. ខ្យល់<br>. គ្មានពណ៌ គ្មានក្លិន គ្មានរស និងមិនអាចមើលឃើញដោយ ភ្នែកទទេបានទេ។ |
| . ចែកសន្លឹកកិច្ចការឱ្យសិស្ស និងណែនាំ<br>. គ្រូឱ្យសិស្សម្នាក់ផឹកទឹកឱ្យអស់ពីកែវ រួចផ្ដល់សំណួរទៅសិស្ស តើពេលដែលប្អូនផឹកទឹកអស់ពីកែវ តើមានសល់អ្វីក្នុងដប?<br>. តើប្អូនត្រូវធ្វើដូចម្ដេចដើម្បីដឹងថាក្នុងកែវមាន សល់អ្វី រឺអត់?<br>. គ្រូធ្វើពិសោធន៍បង្ហាញទី១ (រូបទី១) នឹងប្រាប់សិស្សឱ្យធ្វើការសង្កេត បាតុភូតដែលកើតមាន។<br>. គ្រូធ្វើពិសោធបង្ហាញទី២ (រូបទី២) គ្រូដុតទៀនពីរដើម រួចផ្ដល់សំណួរ តើមានបាតុភូតអ្វីកើតឡើង?មូលហេតុអ្វីបានជាទៀនរលត់?<br>. ខ្យល់ជាអង្គធាតុសុទ្ធ រឺ ល្បាយ? តើក្នុងខ្យល់មានឧស្ម័នអុកស៊ីសែនប៉ុន្មានភាគរយជាមាឌ? | ជំហានទី៣(៤០នាទី)<br>១.សង្កេត (៧នាទី)<br>-រូបទី១<br><br>-មិនឃើញមានទឹកស្រូបចូលក្នុងកែវទេនេះបង្ហាញថាក្នុងកែវមានខ្យល់។<br>-រូបទី២<br><br>ទៀនរលត់ខ្ញុំព្រោះអស់ខ្ញុំអុកស៊ីសែនក្នុងខ្យលខ្ញុំ | មើលសន្លឹកកិច្ចការ គិត និងសរសេរចម្លើយចូល<br>. សង្កេត គិត រួចឆ្លើយ<br>. គ្មានសល់អ្វីទាំងអស់ (ខ្យល់)<br>. រូបទី១ (មិនឃើញមានទឹកស្រូប) ចូលក្នុងកែវទេនេះបង្ហាញ ក្នុងកែវមានខ្យល់។<br>. ទៀនរលត់  មូលហេតុ អស់ឧស្ម័នអុកស៊ីសែន<br>. ក្នុងខ្យល់មានឧស្ម័នអុកស៊ីសែនដែលអាចទ្រទ្រង់ចំហេះ<br>. ខ្យល់ជាល្បាយឧស្ម័ន ជាច្រើន ដូចជាឧស្ម័នអុកស៊ីសែន ,,,,. $O_2$ 78% or $O_2$ 21% ... ជាមាឌនៃខ្យល់ |

| | | |
|---|---|---|
| | ២.សំណួរគន្លឹះ<br>តើត្រូវធ្វើដូចម្ដេចដើម្បីកំណត់ឱ្យដឹងថាអុកស៊ីសែនមាន២១%ក្នុងខ្យល់? | |
| . ផ្ដល់សំណួរគន្លឹះ  ឱ្យសិស្សធ្វើការគិត និងទស្សន៍ទាយលទ្ធផល<br>. កត់ត្រាចំលើយព្រាងទុករបស់សិស្ស<br>. ឱ្យសិស្សគិត ពីប្លង់ពិសោធ ដូចម្ដេចដើម្បីបកស្រាយបានពីសម្មតិកម្ម ដែលគេបានទាយទុក។បើសិស្សធ្វើមិនកើតគ្រូពន្យល់ បង្ហាញ និងណែនាំ<br>. បង្ហាញសិស្សពីរបៀប ប្រើប្រាស់សម្ភារៈពិសោធ បម្រុងប្រយ័ត្ន  និងឱ្យសិស្សធ្វើកាសង្កេត  ឱ្យតំណាងក្រុមឡើងមកយកសម្ភារៈ<br>. ផ្ដល់ឱកាសឱ្យសិស្សធ្វើពិសោធន៍និងស្រង់លទ្ធលផល ដាក់ក្នុងតារាង<br>. ប្រាប់សិស្សពីរបៀបវាស់ មាឌអុកស៊ីសែនក្នុងខ្យល់ គណនាភាគរយ ។<br>. តើក្រោយពេលពិសោធប្អូនសង្កេតឃើញមានអ្វីកើតឡើង? ចូរពន្យល់។<br>. ឱ្យសិស្សទាញសន្និដ្ឋាន តាមសំណួរបំផុស តើឧស្ម័នសំខាន់ក្នុងខ្យល់ជា អ្វី?ប្រាប់មាឌនិង%វាធៀបនឹងមាឌខ្យល់សរុប។ | ៣. សម្មតិកម្ម (៣នាទី)<br>. ដុតទៀន ដាក ថាំនមានទឹក យកកែវគ្របពីលើ<br>. ដាក សំឡីដែកឱ្យមានប្រតិកម្មជាមួយ ខ្យល់<br><br>៤.ប្លង់ពិសោធន៍  និងលទ្ធផល(២៥នាទី)<br><br>. **លទ្ធផល** : ស្រង់ទិន្ន័យបានរាល់៥នាទីម្ដងដាក់ក្នុងតារាង គូសក្រាប និង កំណត់រកមាឌ | . គិត ពិភាក្សា តាមក្រុម រួចគូស ប្លង់ទៅតាមគំនិតរៀងៗខ្លួន<br><br>. ស្ដាប់ មើល សង្កេត<br>. អនុវត្តពិសោធន៍ ជាក្រុមតាមការណែនាំរបស់គ្រូ<br>. វាស់មាឌអុកស៊ីសែនក្នុងខ្យល់ និងគណនា  នូវលទ្ធផល រួចបកស្រាយ និងពន្យល់បាតុភូត នៃពិសោធន៍<br><br>. ស្រង់ទិន្នន័យតាមក្រុម គូសក្រាប ពិភាក្សា គិតគណនារកមាឌ ពិតរបស់អុកស៊ីសែន ។<br>គូសក្រាប និងកំណត់រកមាឌអុកស៊ីសែនពិតតាមក្រាប? គណនាមាឌអុកស៊ីសែនជាភាគរយ? |

| រយៈពេលជានាទី | ០ | ៥ | ១០ | ១៥ | ២០ |
|---|---|---|---|---|---|
| មាឌទឹកស្រូបចូល(ml) | ០ | ៣ | ៧ | ១០ | ១២ |

$$V_{O_2} = \frac{V_{water}}{V_{air}} \times 100 = \frac{12}{57} \times 100$$

| | | |
|---|---|---|
| តើវាស់វាបានដូចម្តេច? | ឧស្ម័នអុកស៊ីសែនពិតក្នុងខ្យល់<br>៥.សន្និដ្ឋាន (៥នាទី)<br>ឧស្ម័នសំខាន់ក្នុងខ្យល់គឺ អុកស៊ីសែន ប្រហែល១/៥(២១%)គិតជាមាឌ គេអាចវាស់បានដោយ ប្រើសំឡីដែកស្រូបអុកស៊ីសែនក្នុងខ្យល់។ | . ធ្វើការសន្និដ្ឋាន រៀងខ្លួន និងពិភាក្សាសំរេចជាក្រុម ។ |
| . តើក្នុងខ្យល់ឧស្ម័នដែលសំខាន់ជាងគេជាអ្វី?<br>. ចូរប្រាប់ពីភាគរយជាមាឌនៃឧស្ម័នអុកស៊ីសែន និងអាសូត ដែលមានក្នុងខ្យល់ ? | ជំហានទី៤(៨នាទី)<br>ពង្រឹងពុទ្ធិ<br>ភាគរយជាមាឌនៃសមាសភាពខ្យល់ | . ឧស្ម័នសំខាន់ៗក្នុងខ្យល់ គឺ អុកស៊ីសែន និងអាសូត<br>. អុកស៊ីសែន ប្រហែល1/5(21%) និង អាសូត 4/5(78%)គិតជាមាឌក្នុងខ្យល់សរុប។ ។ |
| ១. ក្រៅពីឧស្ម័នអុកស៊ីសែន តើមានឧស្ម័នអ្វីខ្លះទៀតក្នុងខ្យល់?<br>២. ប្រាប់ពីភាគរយនៃសមាសធាតុផ្សេងៗដែល មានក្នុងខ្យល់មាន ? | ជំហានទី៥(២នាទី)<br>កិច្ចការផ្ទះ | សិស្សកត់ត្រា រួចយកទៅ ធ្វើនៅផ្ទះ |

# សន្លឹកកិច្ចការ

## ការកំណត់បរិមាណឧស្ម័នអុកស៊ីសែនក្នុងខ្យល់

១. សង្កេត (៥នាទី)

រូបទី១ រូបទី២





....................................... ...............................................

....................................... ...............................................

២. សំណួរគន្លឹះ (ចូរសរសេរសំណួរគន្លឹះលើក្តារខៀនដាក់ក្នុងប្រអប់ខាងក្រោមនេះ

៣. សម្មតិកម្ម (៥នាទី) ចូរប្អូនធ្វើការគិត និងព្រាងទុកនូវចម្លើយ ដែលគិតថាត្រឹមត្រូវ

---

---

៤. រៀបចំប្លង់ និងពិសោធ(២៥នាទី)

តើត្រូវរៀបចំប្លង់ពិសោធដូចម្តេចដើម្បីកំណត់បានបរិមាណអុកស៊ីសែនខាងលើ?

លទ្ធផលៈ ចូរស្រង់លទ្ធផលក្នុង៥នាទីម្តងដាក់ចូលក្នុងតារាង

| រយៈពេលជានាទី | 0 | 5 | 10 | 15 | 20 |
|---|---|---|---|---|---|
| មាឌទឹកស្រូបចូល (ml) | | | | | |

ចូរគូសក្រាបនឹងកំណត់រកមាឌអុកស៊ីសែនពិតតាមក្រាប? ចូរគណនាមាឌអុកស៊ីសែនជាភាគរយ។

| | | | | |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |

៥. សន្និដ្ឋាន (៥នាទី)

៦. កិច្ចការផ្ទះ:

១. តើមានបរិមាណសារធាតុអ្វីខ្លះទៀតក្រៅពីឧស្ម័នសំខាន់ដែលមានក្នុងខ្យល់?

២. បានពីភាគរយនៃសមាសធាតុផ្សេងៗដែលមានក្នុងខ្យល់មាន?

# ១.៣. ជីវវិទ្យា

# កិច្ចតែងការបង្រៀន

មុខវិជ្ជាៈ ជីវវិទ្យា
ថ្នាក់ទី៧ (កម្មវិធីសិក្សាថ្មី)
ជំពូកទី៣ៈ រុក្ខជាតិ
មេរៀនទី២ៈ ដំណឹកនាំក្នុងរុក្ខជាតិមានផ្កា
២. ប្រព័ន្ធដំណឹកនាំរុក្ខជាតិ
រយៈពេលៈ ៥០នាទី

I. វត្ថុបំណងៈ

- ចំណេះដឹង
  –ពន្យល់ពីភាពខុសគ្នានៃការតំរៀបស៊ីឡែមនៅក្នុងដើមរុក្ខជាតិម៉ូណូកូទីលេដូន និង ឌីកូទីលេដូនបានត្រឹមត្រូវតាមរយៈការពិសោធន៍
  – បញ្ជាក់ពីមុខងាររបស់ស៊ីឡែមក្នុងការដឹកនាំ(ទឹក និងសារធាតុខនិជ) ពីឫសទៅកាន់ដើម និងស្លឹកបានច្បាស់លាស់តាមរយៈការពិសោធន៍
- បំណិន
  – កាត់ខ្នាត់ដើមរុក្ខជាតិបានត្រឹមត្រូវតាមរយៈការណែនាំរបស់គ្រូ
  – ប្រើប្រាស់មីក្រូទស្សន៍បានត្រឹមត្រូវតាមរយៈការណែនាំរបស់គ្រូ
- ឥរិយាបថ
  – ថេះថៃរក្សារុក្ខជាតិបានត្រឹមត្រូវតាមរយៈការស្រោចទឹក និងដាក់ជី។

II. សម្ភារៈ

ដើមរាសី ដើមផ្កាក្រចក ដើមមមាញ ដើមចេកទេស ល័ក្ខក្រហម ទឹក កែវ មីក្រូទស្សន៍ បន្ទះឡាមឡាមែល និងឡាមកោរពុកមាត់...

III. ដំណឹកនាំមេរៀនៈ

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| ជំហានទី១ លំនឹងថ្នាក់ (២–៣នាទី) | | |
| .ស្វាគមន៍សិស្ស<br>.ពនិត្យមើលក្នុងថ្នាក់ | .ស្វាគមន៍ និងរដ្ឋបាលថ្នាក់ | .ស្វាគមន៍គ្រូ<br>.ស្តាប់គ្រូ |
| ជំហានទី២ រំលឹកមេរៀនចាស់ (៣–៥នាទី) | | |
| .តើបាច់សរសៃនាំរបស់រុក្ខជាតិមានអ្វីខ្លះ?<br>.តើស៊ីឡែមមានមុខងារអ្វី? | .បាច់សរសៃនាំរបស់រុក្ខជាតិមានស៊ីឡែម និងផ្លូអែម<br>. ដឹកនាំទឹក និងសារធាតុខនិជទៅកាន់ដើម និងស្លឹក។ | .សិស្សឆ្លើយជាក្រុម និងជាបុគ្គល |

| ជំហានទី៣ មេរៀនប្រចាំថ្ងៃ (៣០–៣៥នាទី) | | |
|---|---|---|
| .សរសេរចំណងជើងប្រធានបទលើក្តារខៀន | ប្រធានបទ: *បាច់សរសៃនាំរុក្ខជាតិម៉ូណូកូទីលេដូន និងឌីកូទីលេដូន*<br>**លំនាំបញ្ហា និងសំណួរគន្លឹះ** | |
| .បង្ហាញពីការបឺតយកសូលុយស្យុងល័ក្ខដោយប្រើបំពង់បឺតតូច។ តើមានអ្វីកើតឡើងនៅពេលយើងបឺតសូលុយស្យុងចូលក្នុងបំពង់? | .នៅពេលយើងបឺតសូលុយស្យុងល័ក្ខចូលក្នុងបំពង់តូចនោះ សូលុយស្យុងល័ក្ខនឹង ចូលក្នុងបំពង់ហើយវាមានពណ៌ក្រហម។ | .សិស្សឆ្លើយជាទូទៅនៅក្នុង ថ្នាក់ទាំងមូល |
| .បង្ហាញពីការត្រាំរុក្ខជាតិនៅក្នុងសូលុយស្យុងល័ក្ខ។ តើមានអ្វីកើតឡើង? |  | .ទឹកល័ក្ខនឹងចូលទៅក្នុងស៊ីឡែមរបស់រុក្ខជាតិ ហើយមានពណ៌ក្រហម។ |
| .តើនៅក្នុងដើមរុក្ខជាតិមានស៊ីឡែមប៉ុន្មាន? | .នៅក្នុងដើមរុក្ខជាតិមានស៊ីឡែមច្រើន | .សិស្សគិតហើយឆ្លើយជាទូទៅ និងជាបុគ្គល។ |
| **តើស៊ីឡែមនៅក្នុងរុក្ខជាតិម៉ូណូកូទីលេដូន និងឌីកូទីលេដូនតំរៀបយ៉ាងដូចម្តេច?** | | |
| (ចែកសន្លឹកកិច្ចការ)<br>.បិទរូបភាពខ្នាត់ទទឹងដើមរុក្ខជាតិមិនទាន់បន្ស៊ីពណ៌នៅលើក្តារខៀន ហើយឲ្យសិស្សរកស៊ីឡែម។<br>(ដំបូងឲ្យសិស្សម្នាក់ៗរកស៊ីឡែម និងបំពេញចន្លោះ នៅក្នុងសន្លឹកកិច្ចការហើយ ទើបឲ្យសិស្សឡើងបំពេញនៅលើក្តារខៀន) | **សម្មតិកម្ម**<br>.ស៊ីឡែមដើមរាសីស្ថិតនៅពាសពេញដើម ស៊ីឡែមរបស់ដើមផ្កាក្រចកស្ថិតកៀនដើមជារង្វង់។<br><br>រូបភាពA: ខ្នាត់ទទឹងដើមរាសី មិនទាន់បន្ស៊ីពណ៌ | .សិស្សបំពេញលើសន្លឹកកិច្ចការ ហើយឡើងបំពេញលើក្តារខៀន។<br><br>រូបភាពB: ខ្នាត់ទទឹងដើមផ្កាក្រចក មិនទាន់បន្ស៊ីពណ៌ |

ស៊ីឡែម

| | | |
|---|---|---|
| .តើរូបភាពមួយណាជាខ្នាត់ទទឹងដើមរុក្ខជាតិម៉ូណូកូទីលេដូន និងមួយណាជាខ្នាត់ ទទឹងដើមឌីកូទីលេដូន? ហេតុអ្វី? | .រូបភាពA ជាខ្នាត់ទទឹងដើមរុក្ខជាតិម៉ូណូកូទីលេដូនពី ព្រោះស៊ីឡែមតំរៀបនៅរាយប៉ាយពាសពេញដើម។ រូបភាពB ជាខ្នាត់ទទឹងដើមរុក្ខជាតិឌីកូទីលេដូនពីព្រោះ ស៊ីឡែមរបស់វាតំរៀបជារង្វង់។ | .សិស្សពិភាក្សាគ្នា ឬក៏ឆ្លើយជាបុគ្គល ហើយសរសេរចំលើយដាក់ក្នុងសន្លឹកកិច្ចការ។ |
| .ពន្យល់ពីដំណើរការពិសោធ និងឲ្យសិស្សមើលដំណើការពិសោធបន្ថែមនៅក្នុងសន្លឹកកិច្ចការ<br><br>.ឲ្យសិស្សយករូបភាព ដែលគូនៅលើក្រដាសធំ ទៅបិទនៅលើក្ដារខៀន។ បន្ទាប់ឲ្យពួកគេពន្យល់ពីលទ្ធផលរបស់ពួកគេដោយសង្កត់ធ្ងន់លើទី តាំងស៊ីឡែម។<br>.យករូបភាពដែលបានត្រៀមទុកទៅបិទលើក្ដារខៀនហើយពន្យល់បន្ថែម។ | **ការធ្វើតេស្តសម្មតិកម្ម**<br>.ដំណើការពិសោធដូចមាននៅក្នុងសន្លឹកកិច្ចការ<br><br><br>រូបភាពD: ការតំរៀបស៊ីឡែមដើមរាសី | .សិស្សធ្វើពិសោធជាដៃគូដោយមានប្រើមីក្រូទស្សន៍មួយ។ សិស្សគូរូបនៅក្នុងសន្លឹកកិច្ចការ ហើយនឹងនៅលើក្រដាសធំ។<br><br><br><br>រូបភាពE: ការតំរៀបស៊ីឡែមដើមផ្កាក្រចក |
| .សិស្សម្នាក់ឡើងសរសេរសន្និដ្ឋានរបស់គេនៅលើក្ដារខៀន ហើយសិស្សដទៃ ឡើងបំពេញបន្ថែមនូវចំណុចខ្វះខាត។ | .ស៊ីឡែមរបស់ដើមរាសីនៅ រាយប៉ាយពាសពេញដើមចំណែកស៊ីឡែមរបស់ដើម ផ្កាក្រចកតំរៀបជារង្វង់។<br><br>**សន្និដ្ឋាន**<br>ស៊ីឡែមនៅក្នុងដើមរុក្ខជាតិម៉ូណូកូទីលេដូន និងឌីកូទីលេដូនតំរៀបមិនដូចគ្នាទេ។ នៅក្នុងដើមរុក្ខជាតិម៉ូណូកូទីលេដូនស៊ីឡែមតំរៀបនៅរាយប៉ាយពាសពេញដើម ចំណែកនៅក្នុងរុក្ខជាតិ ឌីកូទីលេដូន ស៊ីឡែមតំរៀបជារង្វង់។ | .សិស្សយករូបភាពទៅបិទនឹងក្ដារខៀន។ បន្ទាប់មកធ្វើការពន្យល់សួរគ្នាទៅវិញទៅមក និងធ្វើការបកស្រាយដោយផ្អែកលើលទ្ធផលរបស់ខ្លួន។<br><br>.សិស្សកែលម្អរការសន្និដ្ឋានរបស់គេឡើងវិញ។ |

| ជំហានទី៤ ពង្រឹងពុទ្ធិ (៤–៥នាទី) | | |
|---|---|---|
| .គ្រូបង្ហាញខ្នាត់ទទឹងដើមចេកទេស ហើយសួរតើវាជាខ្នាត់ទទឹងដើមរុក្ខជាតិម៉ូណូកូទីលេដូន ឬឌីកូទីលេដូន? ព្រោះអ្វី? |  | .វាខ្នាត់ទទឹងដើមរុក្ខជាតិម៉ូណូកូទីលេដូន ពីព្រោះស៊ីឡែមរបស់របស់វាស្ថិតរាយប៉ាយពាសពេញដើម។ |
| .គ្រូបង្ហាញខ្នាត់ទទឹងដើមមមាញ ហើយសួរ តើវាជាខ្នាត់ទទឹងដើមរុក្ខជាតិ ម៉ូណូកូទីលេដូនឬឌីកូទីលេដូន? ព្រោះអ្វី? |  ខ្នាត់ទទឹងដើមមមាញ | .វាជាខ្នាត់ទទឹងដើមរុក្ខជាតិឌីកូទីលេដូន ពីព្រោះស៊ីឡែមរបស់វាតំរៀបជារង្វង់។ |
| ជំហានទី៥ កិច្ចការផ្ទះ (២–៣នាទី) | | |
| .ថ្ងៃនេះយើងបានពិនិត្យស៊ីឡែមរបស់ដើមរុក្ខជាតិ ប្រសិនបើយើងចង់ពិនិត្យពីផ្លូអែមរបស់រុក្ខជាតិវិញ តើយើងត្រូវធ្វើពិសោធយ៉ាងដូចម្ដេច? ចូរធ្វើប្លង់ពិសោធ។ | .វាជាការពិបាកក្នុងការពិនិត្យផ្លូអែមរបស់រុក្ខជាតិ។ គេប្រើសារធាតុវិទ្យុសកម្មដើម្បី ដៅលើអាតូមកាបូនរបស់ឧស្ម័នកាបូនិចដែលប្រើប្រាស់សម្រាប់រុក្ខជាតិធ្វើរស្មីសំយោគ។ | .សិស្សកត់ត្រាហើយព្យាយាមធ្វើប្លង់ពិសោធនៅផ្ទះ។ |

# សន្លឹកកិច្ចការ

ប្រធានបទៈ **បាច់សរសៃនាំរុក្ខជាតិម៉ូណូកូទីលេដូន និងឌីកូទីលេដូន**

បាច់សរសៃនាំរុក្ខជាតិម៉ូណូកូទីលេដូន និងឌីកូទីលេដូនមានពីរប្រភេទគឺ ស៊ីឡែម និង ផ្លូអែម។ ផ្លូអែម ដឹកនាំផលិតផលរស្មីសំយោគ(គ្លុយកូស) ទៅកាន់ដើម និងឬស។ ស៊ីឡែម ដឹកនាំទឹក និង សារធាតុខនិជពីឬសទៅកាន់ដើម និងស្លឹក។

## I. សំណួរគន្លឹះ

នៅក្នុងដើមរុក្ខជាតិមានស៊ីឡែមជាច្រើន។

| |
|---|
| **តើស៊ីឡែមនៅក្នុងរុក្ខជាតិម៉ូណូកូទីលេដូន និងឌីកូទីលេដូនតំរៀបយ៉ាងដូចម្ដេច?** |

## II. សម្មតិកម្ម

ចូរចង្អុលបង្ហាញពីទីតាំងស៊ីឡែមនៅក្នុងខ្នាត់ទទឹងដើមរបស់រុក្ខជាតិខាងក្រោម។



រូបភាពA: ខ្នាត់ទទឹងដើមរុក្ខជាតិមិនទាន់បន្ស៊ីពណ៌



រូបភាពB: ខ្នាត់ទទឹងដើមរុក្ខជាតិមិនទាន់បន្ស៊ីពណ៌

រូបភាពA ជាខ្នាត់ទទឹងរបស់រុក្ខជាតិ..................................ពីព្រោះ......................

..........................................................................................................................

រូបភាពB ជាខ្នាត់ទទឹងរបស់រុក្ខជាតិ...................................ពីព្រោះ.....................

...................................................................................................................

## III. ដំណើការពិសោធ



១. ដាក់ត្រាំរុក្ខជាតិនៅក្នុងសូលុយស្យុងល័ក្ខក្រហម
រយៈពេល២ ទៅ ៣ម៉ោង (គ្រូរៀបចំទុកមុនពេលបង្រៀន)។

២. កាត់ខ្នាត់ទទឹងដើមរាសី(រុក្ខជាតិម៉ូណូកូទីលេដូន)ជាមួយនឹងឡាម (កាត់ឲ្យស្តើងតាមដែលអាចធ្វើទៅបាន)។

៣. ដាក់ខ្នាត់ទទឹងនោះលើបន្ទះឡាមរួចពនិត្យមើលដោយមីក្រូទស្សន៍ (ប្រើកែវពង្រីកវត្ថុតូចជាងគេ)។

៤. គូររូបដែលពិនិត្យឃើញក្នុងមីក្រូទស្សន៍នៅក្នុង
សន្លឹកកិច្ចការ (ឬលើក្រដាសធំ)។

៥. ធ្វើដូចចំណុចពីរដែរចំពោះដើមផ្កាក្រចក(រុក្ខជាតិឌីកូទីលេដូន)។

## IV. លទ្ធផល

ចូរគូររូបខ្នាត់ទទឹងដើមដែលអ្នកពិនិត្យឃើញតាមមីក្រូទស្សន៍ដោយបញ្ជាក់ពីទីតាំងស៊ីឡែម។

រូបភាពD: ខ្នាត់ទទឹងដើមរុក្ខជាតិបន្ទុំពណ៌

រូបភាពE: ខ្នាត់ទទឹងដើមរុក្ខជាតិបន្ទុំពណ៌

## V. សន្និដ្ឋាន

............................................................................................................................................................

............................................................................................................................................................

............................................................................................................................................................។

# ប្លង់ភ្ការមេរៀន

ប្រធានបទ: បាច់សរសៃនាំរុក្ខជាតិម៉ូណូកូទីលេដូន និងឌីកូទីលេដូន

## I. សំណួរគន្លឹះ

| តើស៊ីឡែមនៅក្នុងរុក្ខជាតិម៉ូណូកូទីលេដូន និងឌីកូទីលេដូនតំរៀបយ៉ាងដូចម្ដេច? |
|---|

## II. សម្មតិកម្ម




រូបភាពA: ខ្នាត់ទទឹងដើមរាសីមិនទាន់បន្ស៊ីពណ៌ (រុក្ខជាតិម៉ូណូកូទីលេដូន)

រូបភាពB: ខ្នាត់ទទឹងដើមផ្កាក្រចកមិនទាន់បន្ស៊ីពណ៌ (រុក្ខជាតិឌីកូទីលេដូន)

## III. ដំណើការពិសោធ

សូមអានដំណើការពិសោធន៍នៅក្នុងសន្លឹកកិច្ចការ។

## IV. លទ្ធផល

| រូបភាពសិស្សគូ |
|---|
| រូបភាពសិស្សគូ |
| រូបភាពសិស្សគូ |




រូបភាពD: ការតំរៀបស៊ីឡែមដើមរាសី

រូបភាពE: ការតំរៀបស៊ីឡែមដើមផ្កាក្រចក

## V. សន្និដ្ឋាន

ស៊ីឡែមនៅក្នុងដើមរុក្ខជាតិម៉ូណូកូទីលេដូន និងឌីកូទីលេដូនតំរៀបមិនដូចគ្នាទេ។ នៅក្នុងដើមរុក្ខជាតិម៉ូណូកូទីលេដូន ស៊ីឡែមតំរៀបនៅរាយប៉ាយពាសពេញដើម ចំណែក នៅក្នុងរុក្ខជាតិ ឌីកូទីលេដូន ស៊ីឡែមតំរៀបជារង្វង់។

# កិច្ចតែងការបង្រៀន

ថ្នាក់ទី៧
ជំពូក៤៖ ការរំលាយអាហារ
មេរៀន៖ ការរំលាយអាហារ
៣.ដំណើរការរំលាយអាហារ
៣.៤ ការរំលាយអាហារក្នុងពោះវៀនតូច
រយៈពេល ៖៥០នាទី

I.**វត្ថុបំណង** ៖ -បកស្រាយលំនាំនៃការរំលាយអាហារបានច្បាស់តាមរយៈការពិសោធន៍។
-ប្រើប្រាស់សម្ភារៈពិសោធន៍បានសមស្របតាមខ្លឹមសារមេរៀន។
-ថែរក្សាសុខភាពបានល្អតាមរយៈញុំាអាហារទៀងទាត់ពេលវេលា

II.**សម្ភារៈ** ៖ កែវជ័រចំនួន៤ បាយម៉ាន ថ្នាំពេទ្យជួយរំលាយអាហារ ទឹក ទឹកក្ដៅ(៤០°C) ស្លាបព្រាបាយចំនួន៤ សូលុយស្យុងអ៊ីយ៉ូត សូលុយស្យុងទឹកមាត់។

III.**ដំណើរការបង្រៀន**

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| | ជំហានទី១(២នាទី) | |
| ពង្រឹងវិន័យ និងត្រួតពិនិត្យសណ្ដាប់ធ្នាប់ | រដ្ឋបាលថ្នាក់ | សិស្សរាយការណ៍ |
| | ជំហានទី២(៣-៥នាទី) | |
| .តើអាហារដែលយើងបរិភោគត្រូវបានបំបែកយ៉ាងដូចម្ដេច?<br><br>.នៅក្នុងមាត់ អាមីដុងក្នុងអាហារត្រូវបានបំបែកយ៉ាងដូចម្ដេច? | រំលឹកមេរៀនចាស់<br>៣.ដំណើរការរំលាយអាហារ<br><br>អាមីដុង ⟶ ស្ករងាយ | .អាហារដែលយើងបរិភោគត្រូវបំបែកជាដំណាក់ៗដូចជាក្នុងមាត់ ក្នុងបំពង់អាហារ ក្នុងក្រពះ ក្នុងពោះវៀនតូច។<br>.អាមីដុងក្នុងអាហារត្រូវបានបំបែកទៅជាម៉ូលេគុលស្ករដោយអង់ស៊ីមក្នុងទឹកមាត់។ |
| | ជំហានទី៣(៣០-៣៥នាទី) | |
| .ពេលប្អូនញុំាអាហារចូលទៅហើយមានអារម្មណ៍ថា ឆ្អល់ពោះ។ តើប្អូនគិតដូចម្ដេច?តើដោះស្រាយតាមវិធីណា?<br>រវាងការប្រើថ្នាំរំលាយអាហារនិងមិន | **មេរៀនថ្មី៖ការរំលាយអាហារ**<br>៣.៤ ការរំលាយអាហារក្នុងពោះវៀនតូច | .អាហារមិនរលាយ<br>.គឺប្រើថ្នាំជួយរំលាយអាហារ |

| | | |
|---|---|---|
| ប្រើថ្នាំ តើរយៈពេលនៃការបាត់ឆ្អល់<br>ពោះដូចគ្នាឬទេ? | **សំណួរគន្លឹះ** | .ខ្លះដូចគ្នា ឬបាត់ឆ្អល់លឿន<br>.ខ្លះអត់ដូចឬបាត់ឆ្អល់យូរ |
| **តើអ្នកអាចបង្កើនល្បឿននៃការបំបែកអាហារយ៉ាងដូចម្តេច?** | | |
| .បង្ហាញថ្នាំរំលាយអាហារដល់<br>សិស្ស៖<br>.ចូរធ្វើការទស្សន៍ទាយ ៖ | .ឈ្មោះថ្នាំរំលាយអាហារមាន<br>PANTYRAS-K , ENZYPLEX<br>**សម្មតិកម្ម** | .សង្កេត និងកត់ឈ្មោះថ្នាំ<br>.ពិនិត្យសង្កេត គិត រួចឆ្លើយ |
|  | | |
| -តើកែវមួយណាបំបែកអាមីដុង<br>អស់មុនគេ?<br>.ចង់ដឹងថា ការគិតរបស់ប្អូនបាន<br>ត្រឹមត្រូវឬទេយើងនាំគ្នាធ្វើពិសោធ<br>ន៍។<br>.ចែកសិស្ស៨នាក់មួយក្រុម<br>.តើយើងអាចធ្វើពិសោធន៍លើ<br>ប្រភេទអាហារអ្វីខ្លះ?<br>តែថ្ងៃនេះគ្រូលើកយកបាយម៉ាន<br>មកធ្វើការពិសោធន៍។<br>.ណែនាំសិស្សឲ្យធ្វើពិសោធន៍តាម<br>លំនាំក្នុងសន្លឹកកិច្ចការ។<br>.កំណត់ពេលវេលាពិសោធន៍ ដល់<br>សិស្ស។<br>.ដើរពិនិត្យមើលសិស្សតាមក្រុម<br>.ឲ្យសិស្សធ្វើការវិភាគលើលទ្ធផល<br>ពិសោធន៍របស់ពួកគេ។ | **ពិសោធ**<br>.សម្ភារៈ<br>.ដំណើរការពិសោធន៍ | សិស្សខ្លះថា៖<br>.កែវ B<br>.កែវ C<br>.កែវ D<br>.សិស្សអង្គុយតាមក្រុម<br>.ប្រភេទអាហារផ្សេងៗ៖<br>បាយ សាច់ ខ្លាញ់...<br>.ក្រុមសិស្សនីមួយៗ នាំគ្នាធ្វើ<br>ពិសោធន៍តាមលំនាំក្នុងសន្លឹកកិច្ច<br>ការ។<br>.សង្កេតមើលលទ្ធផល |

| កែវ | សង្កេត | | |
|---|---|---|---|
| | មុនពិសោធន៍ | ក្រោយពិសោធន៍ | |
| | លក្ខណៈសូលុយស្យុង | លក្ខណៈសូលុយស្យុង | ពណ៌ |
| A | បាយម៉ានខាប់ | បាយម៉ាននៅខាប់ដដែល | ខៀវចាស់ |
| B | បាយម៉ានខាប់ | បាយម៉ាននៅខាប់ដដែល | ខៀវចាស់ |
| C | បាយម៉ានខាប់ | បាយម៉ានមានសភាពរាវ | ខៀវចាស់ |
| D | បាយម៉ានខាប់ | បាយម៉ានក្លាយជារាវ | គ្មានពណ៌ |

.សិស្សសរសេរលទ្ធផលក្នុងសន្លឹកកិច្ចការ។ បន្ទាប់មកវិភាគលទ្ធផល។
.សិស្សធ្វើការប្រៀបធៀបលទ្ធផលទៅនិងសម្មតិកម្ម របស់ខ្លួន។



A.ទឹកត្រជាក់ B.ទឹកក្តៅ C.សូលុយស្យុងទឹកមាត់ D.សូ.ថ្នាំរំលាយអាហារ

| | | |
|---|---|---|
| .ឲ្យសិស្សទាញសន្និដ្ឋាន | **សន្និដ្ឋានៈ**<br>.ការបំបែកអាហារ ដោយមានការចូលរួមពីអង់ស៊ីម ធ្វើឲ្យប្រតិកម្មនៃការរំលាយអាហារ ប្រព្រឹត្តទៅបានលឿន ងាយ រំលាយ។<br>.ការរំលាយអាហារដោយប្រើអង់ស៊ីម ហៅថាការរំលាយអាហារបែបគីមី | សិស្សសន្និដ្ឋានៈ<br>.កែវដែលមានថ្នាំរំលាយអាហារបំបែកបានលឿនជាងគេ។<br>.ការរំលាយអាហារដោយប្រើអង់ស៊ីម ហៅថាការរំលាយអាហារបែបគីមី ។ |
| <u>ជំហានទី៤</u> (៤-៥នាទី) | | |
| .តើអ្វីជា ការរំលាយអាហារតាមបែបគីមី?<br>.តើលំនាំនៃការរំលាយអាហារនៅក្នុងពោះវៀនតូចប្រព្រឹត្តទៅដូចម្តេច? | ពង្រឹងពុទ្ធិ<br>អាមីដុង ⟶ ស្ករងាយ<br>ប្រូតេអ៊ីន ⟶ អាស៊ីតអាមីនេ<br>ខ្លាញ់ ⟶ អាស៊ីត+គ្លីសេរ៉ុល | .គឺជាការរំលាយអាហារដោយមានការចូលរួមពីអង់ស៊ីម<br>.ម៉ូលេគុលអាហារត្រូវបានបំបែកជាម៉ូលេគុលងាយៗ |
| <u>ជំហានទី៥</u> (៣-៤នាទី) | | |
| ចូរធ្វើពិសោធពីការរំលាយ អាហារលើអាហារផ្សេងទៀត | កិច្ចការផ្ទះ | សិស្សកត់ត្រា |

# សន្លឹកកិច្ចការ

ប្រធានបទ  ការរំលាយអាហារ

សំណួរគន្លឹះ: **តើអ្នកអាចបង្កើនល្បឿននៃការបំបែកអាហារយ៉ាងដូចម្តេច?**

សម្មតិកម្ម  ចូរសង្កេតមើលការពិសោធន៍ខាងក្រោម




.តើកែវមួយណាបំបែកអាមីដុងអស់មុនគេ?

..........................................................................................................................

..........................................................................

..........................................................................................................................

..........................................................................

**ដំណើរការពិសោធន៍**

- ដាក់បាយម៉ានក្នុងកែវទាំងបួន(A,B,C,D)
- បន្ទាប់មកបន្ថែម៖
- ទឹកត្រជាក់  ២០ម.ល ទៅក្នុងកែវ A
- ទឹកក្តៅ  ២០ ម.ល ទៅក្នុងកែវ B
- ទឹកមាត់  ២០ ម.ល ទៅក្នុងកែវ C
- សូ.ថ្នាំរំលាយអាហារ  ២០ ម.ល ទៅក្នុងកែវ D

កែវនីមួយៗត្រូវកូរឲ្យសព្វ រយៈពេល ៥ នាទី រួចដាក់សូ.អ៊ីយ៉ូត  ហើយសង្កេតមើលលទ្ធផល  និងកត់ចូលក្នុងតារាងលទ្ធផល។

**លទ្ធផល**

| កែវ | សង្កេត | | |
|---|---|---|---|
| | មុនពិសោធន៍ | ក្រោយពិសោធន៍ | |
| | លក្ខណៈសូលុយស្យុង | លក្ខណៈសូលុយស្យុង | ពណ៌ |
| A | | | |
| B | | | |
| C | | | |
| D | | | |

**សន្និដ្ឋាន**

..........................................................................................................................

..........................................................................................................................

# ប្លង់ក្តារខៀន

ប្រធានបទ៖ ការរំលាយអាហារ

**សំណួរគន្លឹះ**

> តើអ្នកអាចបង្កើនល្បឿននៃការបំបែកអាហារយ៉ាងដូចម្តេច?

**សម្មតិកម្ម**




- កែវAនិង B មានពណ៌ខៀវចាស់
- កែវ C បំបែកអស់ ព្រោះមានទឹកមាត់ និងមានពណ៌ត្នោត
- កែវ D បំបែកអស់ព្រោះមានថ្នាំរំលាយអាហារ និងមានពណ៌ត្នោត

**ពិសោធ**

- សម្ភារៈ
- ដំណើរការពិសោធន៍

**លទ្ធផល**

| កែវ | សង្កេត | | |
|---|---|---|---|
| | មុនពិសោធន៍ | ក្រោយពិសោធន៍ | |
| | លក្ខណៈសូលុយស្យុង | លក្ខណៈសូលុយស្យុង | ពណ៌ |
| A | បាយម៉ានខាប់ | បាយម៉ាននៅខាប់ដដែល | ខៀវចាស់ |
| B | បាយម៉ានខាប់ | បាយម៉ាននៅខាប់ដដែល | ខៀវចាស់ |
| C | បាយម៉ានខាប់ | បាយម៉ានមានសភាពរាវ | ខៀវចាស់ |
| D | បាយម៉ានខាប់ | បាយម៉ានក្លាយជារាវ | គ្មានពណ៌ |




**សន្និដ្ឋាន**

.ការបំបែកអាហារ ដោយមានការចូលរួមពីអង់ស៊ីម ធ្វើឲ្យប្រតិកម្មនៃ ការរំលាយអាហារ ប្រព្រឹត្តទៅបានលឿន ងាយ រំលាយ។

.ការរំលាយអាហារដោយប្រើអង់ស៊ីម ហៅថាការរំលាយអាហារបែបគីមី ។

# កិច្ចតែងការបង្រៀន

ថ្នាក់ទី៧

ជំពូកទី២ រុក្ខជាតិ

មេរៀនទី៣ ដំណឹកនាំក្នុងរុក្ខជាតិមានផ្កា

១.២ . អូស្មូស (ការសាកល្បង) រយៈពេល ៥០ នាទី

## I. វត្ថុបំណង

- បកស្រាយបាតុភូតអូស្មូសបានច្បាស់លាស់តាមរយៈការពិសោធន៍។
- ប្រើប្រាសសម្ភារៈពិសោធន៍បានសមស្របតាមខ្លឹមសារមេរៀន។
- ថែរក្សារុក្ខជាតិបានល្អតាមរយៈការស្រោចទឹកត្រឹមត្រូវ។

## II. សម្ភារៈ

ត្រកួន ទឹក អំបិល កែវជ័រ កូនកាំបិតឬឡាម និងកូនស្លាបព្រា។

## III. ដំណើរការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| | ជំហានទី១(២–៣នាទី) | |
| ពង្រឹងវិន័យ និងត្រួតពិនិត្យសណ្ដាប់ធ្នាប់។ | (រដ្ឋបាលថ្នាក់) | សិស្សរាយការណ៍ |
| | ជំហានទី២(៤–៥នាទី) | |
| ១. តើរុក្ខជាតិថ្នាក់ទាបដឹកនាំសារធាតុផ្សេងៗចេញ និង ចូលកោសិកាយ៉ាងដូចម្តេច?<br>២. ចំពោះរុក្ខជាតិថ្នាក់ខ្ពស់ដូចជារុក្ខជាតិមានផ្កាវិញ តើការដឹកនាំសារធាតុផ្សេងៗចេញ និងចូលកោសិកាប្រព្រឹត្តទៅ យ៉ាងដូចម្តេចដែរ? | (រំលឹកមេរៀនចាស់) | ១.រុក្ខជាតិថ្នាក់ទាបដឹកនាំសារធាតុ ផ្សេងៗចេញ និងចូលកោសិកាតាមរយៈបន្សាយ។<br>២.រុក្ខជាតិថ្នាក់ខ្ពស់កោសិការបស់វាស្ថិតនៅជ្រៅ និងឆ្ងាយពីផ្ទៃខាងលើនៃសារពាង្គកាយ។ ដូចនេះ ដើម្បីដឹកនាំសារធាតុផ្សេងៗចេញនិងចូលកោសិកា វាមានដំណឹកនាំច្រើនរបៀបដូចជា អូស្មូស ជាដើម។ |
| | ជំហានទី៣(៣០–៣៥នាទី) | |
| ឲ្យសិស្សគិតទាក់ទងទៅនឹងជីវភាពប្រចាំថ្ងៃ | មេរៀនថ្មី ដំណឹកនាំក្នុងរុក្ខជាតិមានផ្កា ១.២ អូស្មូស | សិស្សគិតទៅលើបាតុភូតនោះ ហើយឆ្លើយសំនួរ |

| | | |
|---|---|---|
| <br>ហេតុអ្វីបានជារុក្ខជាតិក្នុងកែវទាំងពីរមានសភាពខុសគ្នា? | – សូលុយស្យុងខុសគ្នា កែវ A ទឹកធម្មតា កែវ B ទឹកអំបិល<br><br>១ សំនួរគន្លឹះ | A: សូលុយស្យុងខុសគ្នា កែវ A ទឹកធម្មតា កែវ B ទឹកអំបិល<br>B: សូលុយស្យុងខុសគ្នា កែវ A ទឹកធម្មតា កែវ B ទឹកស្ករ |

**ពេលយើងដាក់រុក្ខជាតិដូចគ្នា មួយទៅក្នុងកែវទឹកធម្មតា និងមួយទៀតទៅក្នុងកែវទឹកអំបិល តើមានអ្វីកើតឡើង?**

| | | |
|---|---|---|
| ចូរទស្សន៍ទាយមើល តើត្រកួនក្នុងកែវទាំងពីរមានលក្ខណៈយ៉ាងដូចម្ដេច? | ២ សម្មតិកម្ម<br> | សិស្សគិតរួចឆ្លើយ<br>– ត្រកួនក្នុងកែវ A រីកកោងចេញក្រៅ។<br>– ត្រកួនក្នុងកែវ B រួញហើយទន់។ |
| ណែនាំសិស្សមើល និងបំពេញសន្លឹកកិច្ចការ<br><br><br><br>–ចូរសង្កេតមើល ត្រកួនក្នុងកែវទាំងពីរ។ | ៣ ធ្វើពិសោធន៍<br>– សម្ភារៈ<br>– ដំណើរការពិសោធន៍<br>– រៀបចំកែវទឹកពីរ កែវមួយដាក់ ទឹកធម្មតា និងកែវមួយទៀត ដាក់ ទឹកអំបិលប្រហែល ២០ ភាគរយ។<br>– កាត់ត្រកួនប្រវែង ៣ ទៅ ៤ សង់ទីម៉ែត្រ រួចឈូតវាជាបួន ឆ្នូត ទាំងសងខាង ប្រហែល ៤ ទៅ ៦ដុំ។<br>–ដាក់ត្រកួនដែលឈូតរួច នោះទៅក្នុងកែវទាំងពីររួច សង្កេតមើល។ | សិស្សមើលសន្លឹកកិច្ចការ រួចធ្វើពិសោធន៍ |

| | | |
|---|---|---|
| - ចូរផ្ទៀងផ្ទាត់លទ្ធផល ពិសោធន៍ ដែលទទួលបានទៅ នឹងសម្មតិកម្ម របស់អ្នក។<br><br>-តើត្រកួននៅ ក្នុងកែវទាំងពីរមាន លក្ខណៈខុសគ្នាយ៉ាងដូចម្ដេច? ចូរពន្យល់?<br>(ប្រសិន សិស្សមិនអាចឆ្លើយបាន ឲ្យតម្រុយទៅសិស្ស ដោយឲ្យ ប្រៀបធៀបបរិមាណទឹកនៅក្នុងកែវ នឹងបរិមាណទឹកក្នុងកោសិកា ត្រកួន)<br><br>- តាមរយៈលទ្ធផលខាងលើ ចូរទាញសេចក្ដីសន្និដ្ឋាន | **៤ លទ្ធផល**<br><br>- A: កែវទឹកធម្មតារីកឡើងកោង ហើយ មានសភាពរឹង ពីព្រោះនៅ មជ្ឈដ្ឋាន ខាងក្រៅមានបរិមាណទឹក ច្រើននាំឲ្យទឹកធ្វើចលនាចូលក្នុងកោសិកា។<br>- B: ចំណែក ត្រកួនដែលនៅក្នុងកែវ ទឹកអំបិលស្វិត ហើយមានសភាពទន់ ជាងមុន ពីព្រោះនៅមជ្ឈដ្ឋានខាងក្រៅ មានបរិមាណទឹកតិចនាំឲ្យទឹកធ្វើ ចលនាចេញពីកោសិកា។<br>**៥ សន្និដ្ឋាន**<br>តាមរយៈលទ្ធផលពិសោធន៍ យើងអាច ទាញសេចក្ដីសន្និដ្ឋានបានថា ក្នុង កោសិការុក្ខជាតិ ទឹកធ្វើចលនាពីតំបន់ ដែលមានបរិមាណទឹកច្រើនទៅតំបន់ ដែលមានបរិមាណទឹកតិច។ បាតុភូត នៃចលនាទឹកពីតំបន់ដែលមាន បរិមាណទឹកច្រើនទៅតំបន់ដែលមាន បរិមាណទឹកតិចឆ្លងកាត់ភ្នាសអឌ្ឍជ្រាប ហៅថា បាតុភូតអូស្មូស។ | - សិស្សសង្កេត<br><br>- សិស្សធ្វើការផ្ទៀងផ្ទាត់លទ្ធផល ពិសោធន៍ទៅនឹងសម្មតិកម្មរបស់ពួកគេ ឆ្លើយនឹងសំនួរ ហើយបំពេញសន្លឹកកិច្ចការ<br>- កែវ A ត្រកួនមានសភាពរឹងព្រោះ កោសិកាត្រកួនស្រូបទឹកចូល។<br><br>- កែវ B ត្រកួនមានសភាពទន់ ព្រោះ ទឹកចេញពីកោសិកា ត្រកួន។<br><br>- សិស្សទាញសេចក្ដីសន្និដ្ឋានដោយខ្លួនឯង<br>- តាមរយៈទឹកធ្វើចលនាពីតំបន់ដែល មានបរិមាណទឹកច្រើន ទៅតំបន់ ដែល មានទឹកតិច។<br>- គ្រូគ្រាន់តែសម្រប សម្រួល។ |
| ជំហានទី៤(៤-៥នាទី) | | |
| ដាក់បន្លែផ្សេងទៀតក្នុងទឹកធម្មតា និងទឹកអំបិលហើយសួរសិស្ស តើបន្លែមួយណាត្រាំក្នុងទឹកធម្មតា និងមយយណាត្រាំក្នុងទឹកអំបិល? | ពង្រឹងពុទ្ធិ | សិស្សឆ្លើយ |

| ជំហានទី ៥(២-៣នាទី) | | |
|---|---|---|
| ចូរប្អូនធ្វើពិសោធន៍ពីបាតុភូតអូស្មូសលើបន្លែផ្សេងៗទៀត។ | បណ្តាំផ្ញើ<br>កិច្ចការផ្ទះ | សិស្សកត់ត្រា។ |

# សន្លឹកកិច្ចការ

ប្រធានបទ: បាតុភូតអូស្មូស

១ សំនួរគន្លឹះ:

| ពេលយើងដាក់រុក្ខជាតិដូចគ្នា មួយទៅក្នុងកែវទឹកធម្មតា និងមួយទៀត ទៅក្នុងកែវទឹកអំបិល តើមានអ្វីកើតឡើង? |
|---|

២ សម្មតិកម្ម :

កែវ A: ………………………………………………

…………………………………………………………

…………………………………………………………

កែវ B: ………………………………………………

…………………………………………………………

…………………………………………………………




៣ ដំណើរការពិសោធន៍



- សម្ភារៈ:

ត្រកួន ទឹក អំបិល កែវជ័រ កូនកាំបិតឬឡាម និងកូនស្លាបព្រា។

- ដំណើរការ

- រៀបចំកែវទឹកពីរ កែវមួយដាក់ទឹកធម្មតា និងកែវមួយទៀត ដាក់ ទឹកអំបិល ប្រហែល២០ភាគរយ។
- កាត់ត្រកួនប្រវែង ៣ ទៅ ៤ សង់ទីម៉ែត្រ រួចឈូតវាជាបួនឆ្នូត ទាំងសងខាង ប្រហែល ៤ ទៅ ៦ដុំ។
- ដាក់ត្រកួនដែលឈូតរួចនោះទៅក្នុងកែវទាំងពីររួចសង្កេតមើល។

៤ លទ្ធផល

តើត្រកួននៅ ក្នុងកែវទាំងពីរមានលក្ខណៈខុសគ្នាយ៉ាងដូចម្ដេច? ចូរពន្យល់?

- កែវទឹកធម្មតា…………………………………………………………

……………………………………………………………………………………

……………………………………………………………………………………

- កែវទឹកអំបិល…………………………………………………………

……………………………………………………………………………………

……………………………………………………………………………………

៥ សន្និដ្ឋាន

ចូរទាញសេចក្ដីសន្និដ្ឋានតាមរយៈលទ្ធផលពិសោធន៍របស់អ្នក:

……………………………………………………………………………………

……………………………………………………………………………………

……………………………………………………………………………………

……………………………………………………………………………………

……………………………………………………………………………………

# ប្លង់ក្ដារខៀន

ប្រធានបទ: បាតុភូតអូស្មូស

ហេតុអ្វីបានជារុក្ខជាតិក្នុងកែវទាំងពីរមាន សភាពខុសគ្នា?

………………………………………………………………
………………………………………………………………
………………………………………………………………




១ សំនួរគន្លឹះ:

> ពេលយើងដាក់រុក្ខជាតិដូចគ្នា មួយទៅក្នុងកែវទឹកធម្មតា និងមួយទៀត ទៅក្នុងកែវទឹកអំបិល តើមានអ្វីកើតឡើង?

២ ចូរបង្កើតសម្មតិកម្ម:

- ក្នុងកែវ A ទឹកធម្មតាត្រកួន ដែលឆ្ងូត នោះរីកដូចផ្កា ហើយមានសភាពរឹង (ទឹកចូលក្នុងកោសិកា)។

- ក្នុងកែវ B ទឹកអំបិលត្រកួន ដែលឆ្ងូតនោះមិនរីកទេ ហើយមានសភាពទន់ (ទឹកចេញពីកោសិកា)។




៣ ដំណើរការពិសោធន៍

- សម្ភារ:………………………………………………………………
- ដំណើរការ ………………………………………………………………

៤ លទ្ធផល

តើត្រកួននៅក្នុងកែវទាំងពីរមានលក្ខណៈខុសគ្នាយ៉ាងដូចម្ដេច?ចូរ ពន្យល់?

**(ហេតុអ្វីបានជាត្រកួនក្នុងកែវទឹកធម្មតារីកឡើងកោង ហើយមានសភាពរឹង?)**

- ត្រកួនក្នុងកែវទឹកធម្មតា (កែវបន្ទាប់ពីពិសោធន៍)

ត្រកួននៅក្នុងកែវទឹកធម្មតារីកឡើងកោងហើយមានសភាព រឹង ពីព្រោះនៅមជ្ឈដ្ឋានខាងក្រៅមានបរិមាណទឹកច្រើន នាំឲ្យទឹកធ្វើចលនាចូលក្នុងកោសិកា។

**(ហេតុអ្វីបានជាត្រកួនក្នុងកែវទឹកអំបិលស្វិត ហើយមានសភាពទន់?)**

- ត្រកួនក្នុងកែវទឹកអំបិល (កែវបន្ទាប់ពីពិសោធន៍)

ចំណែក ត្រកួនដែលនៅក្នុងកែវទឹកអំបិលនៅធម្មតា តែ មានសភាពទន់ជាងមុន ពីព្រោះនៅមជ្ឈដ្ឋានខាងក្រៅមានបរិមាណទឹកតិចនាំឲ្យទឹកធ្វើចលនា ចេញពីកោសិកា។

៥ សន្និដ្ឋាន

តាមរយៈលទ្ធផលពិសោធន៍ យើងអាចទាញសេចក្ដីសន្និដ្ឋានបានថា ទឹកធ្វើចលនាពីតំបន់ដែលមានបរិមាណទឹកច្រើនទៅតំបន់ដែលមានបរិមាណទឹកតិច។ បាតុភូតនៃចលនាទឹកពីតំបន់ដែលមានបរិមាណទឹកច្រើនទៅតំបន់ ដែលមានបរិមាណ ទឹកតិចឆ្លងកាត់ភ្នាសអឌ្ឍជ្រាប ហៅថា បាតុភូតអូស្មូស។

# ១.៤. ផែនដីវិទ្យា

# កិច្ចតែងការបង្រៀន

I– វត្ថុបំណង

- ពន្យល់បានថាទឹកនៅក្នុងខ្យល់ ឬក្នុងអាកាសមានទំនាក់ទំនងដោយផ្ទាល់ជាមួយសីតុណ្ហភាព
- សង្កេតដោយផ្ទាល់ពីបាតិភូតធម្មជាតិដោយប្រុងប្រយ័ត្ន
- យកចិត្តទុកដាក់ពីបាតុភូតធម្មជាតិនៅក្នុងជីវភាពរស់នៅ

II– សម្ភារបង្រៀន

- ទឹកកកទឹកក្តៅ ដបទឹក ធុងទឹកកក ធុងទឹកក្តៅ កែវទឹក ប្លស្ទិច ក្រដាសអនាម័យ

III– ពាក្យគន្លឹះ

- ទឹកមិនអាចមើលឃើញនៅក្នុងខ្យល់ អ័ព្ទ សីតុណ្ហភាព

IV– សកម្មភាពបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារ | សកម្មភាពសិស្ស |
|---|---|---|
| . បង្ហាញរូបភាពអ័ព្ទហើយសួរសិស្សរូបនេះជាអ្វីអាចកើតឡើងនៅពេលណា?<br>. តើធ្លាប់ដើរឆ្លងកាត់អ័ព្ទដែរឬទេ? តើមានអារម្មណ៍ដូចម្តេច?<br>. តើយើងអាចរកឃើញអ្វីដែលស្រដៀងទៅនិងអ័ព្ទនៅក្នុងជីវភាពរស់នៅរាល់ថ្ងៃ? | ជំហានទី២<br>▪ រូបភាពអ័ព្ទ<br>• ចំហាយទឹកមិនអាចមើលឃើញ<br>• អ័ព្ទ ឬពពកអាចមើលឃើញព្រោះវាជា<br>តំណក់ទឹក។ | . រូបភាពអ័ព្ទ អាចឃើញពេលព្រលឹម និងពេលល្ងាច។ ពពកឃើញញឹកញាប់។<br>. មានអារម្មណ៍ថាត្រជាក់សើម និងមិនអាចមើលជុំវិញខ្លួន។<br>. បើកទូរទឹកកកមានផ្សែងហុយចេញ នៅលើការ៉េមពេលបើកគម្របផ្នាំងបាយ... |
| ចែកសិស្សជាក្រុមតូចៗ (៨ក្រុម) ហើយចែកសន្លឹកកិច្ចការអោយសិស្ស។ បង្ហាញពិសោធមួយ។<br>. ចូរសង្កេតកែវ A និងB តើមានអ្វីកើតឡើង? | ជំហានទី៣<br>កែវ A ទឹកកក   កែវ B ទឹកក្តៅ<br> | . រកឃើញមានផ្សែងហុយពីលើកែវ B និងមានតំណក់ទឹកតូចៗនៅក្នុងកែវ A (អាច |

| | | |
|---|---|---|
| . តើផ្សែងនៅលើកែវ B បានពីអ្វី?<br>. តំណក់ទឹកតូចៗ ជុំវិញកែវ A បានពីអ្វី?<br>ជូតកែវអោយស្អាតគ្របប្លស្ទីចលើកែវទាំងពីអោយជិត<br>. ចូរសង្កេតកែវ A និង B ម្តងទៀតតើមានអ្វីកើតឡើង?<br>. តើតំណក់ទឹកតូចៗជុំវិញកែវ Aបានពីអ្វី? | កែវ A ទឹកកក កែវ B ទឹកក្តៅ<br><br>សម្មតិកម្ម<br>តំណក់ទឹកតូចៗនៅជុំវិញខាងក្រៅកែវ A បានមកពីខ្យល់? | មើលឃើញផ្សែងហុយលើកែវ A)<br>. ផ្សែងនៅលើកែវ B បានពីទឹកក្តៅតំណត់ទឹកតូចៗ ជុំវិញកែវ A បានពីទឹកកក។<br>. មានតំណក់ទឹកតូចៗនៅជាប់តំណក់ទឹកតូចៗនៅជាប់ប្លស្ទីចក្នុងកែវ B បានពីទឹកក្តៅតំណក់ទឹកតូចៗនៅជុំវិញខាងក្រៅកែវ A ។<br>. បានពីខ្យល់??? |
| សំណួរគន្លឹះ **តើអ័ព្ទ(តំណក់ទឹក)បានមកពីណា?** | | |
| . បង្ហាញដបទទេមួយ ហើយសួរសិស្ស៖<br>• តើមានអ្វីនៅក្នុងដបនេះ?<br>• បើដាក់ដបក្នុងទឹកធម្មតាតើមានអ្វីកើតឡើង?<br>• បើដាក់ដបក្នុងទឹកត្រជាក់តើមានអ្វីកើតឡើង? | | . ខ្យល់<br>. គ្មានអ្វីកើតឡើង មានអ័ព្ទមានពពក...។ |
| ចូលសង្កេត តើមានអ្វីកើតឡើងនៅក្នុងដបទទេ? | | |
| ណែនាំសិស្សអោយធ្វើពិសោធន៍<br>១. យកដបទទេហើយស្ងួតហើយដាក់ក្នុងទឹកកក ប្រហែល ៣០វិនាទី។ ចូរសង្កេត។<br>២. បន្ទាប់មកយកទៅដាក់ក្នុងទឹកធម្មតា ប្រហែល៣០ វិនាទី។ ចូរសង្កេត។<br>. សង្កេតដបទឹក ហើយសរសេរលើសន្លឹកកិច្ចការ។ | សកម្មភាព<br>ដបទទេហើយស្ងួត<br>ទឹកត្រជាក់ ទឹកក្តៅ<br> | |

| | | |
|---|---|---|
| . តាមការធ្វើពិសោធន៍ យើងទទួលលទ្ធផលដូចម្តេច?<br>. តាមរយៈលទ្ធផលតើយើងសន្និដ្ឋានបានយ៉ាងដូចម្តេច? | ជំហានទី៤<br>. ចំហាយទឹកក្លាយជាតំណក់ទឹកនៅពេលសីតុណ្ហភាពថយចុះ។<br>. តំណក់ទឹកក្លាយជាចំហាយទឹកនៅពេលសីតុណ្ហភាពកើនឡើង<br>សន្និដ្ឋានៈ មានទឹកនៅក្នុងខ្យល់ឬបរិយាកាសតែយើងមិនអាចមើលឃើញព្រោះវាជាចំហាយទឹក។ ទឹកនៅក្នុងខ្យល់ប្រែប្រួលដោយសារសីតុណ្ហភាព។ | . អាចមើលឃើញអ័ព្ទ។ អ័ព្ទបានពីទឹកនៅក្នុងខ្យល់។ |
| បើយើងហាលសម្លៀកបំពាក់នៅកន្លែងដែលមានសីតុណ្ហភាពខ្ពស់ និងកន្លែងដែលមានសីតុណ្ហភាពទាប តើកន្លែងមួយណាដែលធ្វើអោយសម្លៀកបំពាក់ស្ងួតរហ័សជាងគេ? ហេតុអ្វី | ជំហានទី៥ (កិច្ចការផ្ទះ)<br>យល់ពីរំហួត និងខ្យល់ឆ្អែតចំហាយទឹក។ | សិស្សកត់ត្រា។ |

## សន្លឹកកិច្ចការ

១/ បន្ទាប់គ្រប់កែវតើមានអ្វីខុសគ្នារវាងកែវ A និងកែវ B? ចូរសង្កេត។




.........................................................................................................................................................

.........................................................................................................................................................

. ផ្សែងនៅលើទឹកក្ដៅបានពី.........................................................................................។

២/ តើអ័ព្ទ(តំណក់ទឹក)បានមកពីណា?

.........................................................................................................................................................

.........................................................................................................................................................

. តើអ្នកអាចពិនិត្យយោបល់(សម្មតិកម្ម) របស់អ្នកបានដូចម្ដេច?

.........................................................................................................................................................

.........................................................................................................................................................

៣/ ចូរសង្កេត តើមានអ្វីកើតឡើងនៅក្នុងដបទទេ?

សម្ភារះ

ដបទទេ ធុងទឹកត្រជាក់ ធុងទឹកក្ដៅ







ក/ យកដបដាក់ទៅក្នុងធុងទឹកត្រជាក់ ប្រហែល ៣០វិនាទី។ ចូរសង្កេតដបទឹក តើមានអ្វីកើតឡើង?

.........................................................................................................................................................

.........................................................................................................................................................

ខ/ បន្ទាប់មកយកទៅដាក់ក្នុងធុងធម្មតា ប្រហែល ៣០វិនាទី។ ចូរសង្កេតដបទឹក តើមានអ្វីកើតឡើង?

.........................................................................................................................................................

.........................................................................................................................................................

៤/ សន្និដ្ឋាន

.........................................................................................................................................................

.........................................................................................................................................................

៥/ សំណួរ

.........................................................................................................................................................

## ប្លង់ការរៀន

**ទឹកក្នុងបរិយាកាស**

បង្ហាញរូបភាពអ័ព្ទ: មើលឃើញពេលព្រលឹម និងល្ងាច

សំណួរគន្លឹះ តើអ័ព្ទ(តំណក់ទឹក) បានមកពីណា?

សម្មតិកម្ម: តំណក់ទឹកតូចៗនៅជុំវិញខាងក្រៅកែវ A បានពីខ្យល់?

ចូរសង្កេត៖ តើមានអ្វីកើតឡើងនៅក្នុងដបទទេ?

លទ្ធផល:

- ដបនៅក្នុងទឹកត្រជាក់

- ដបនៅក្នុងទឹកធម្មតា

សន្និដ្ឋាន:

មានទឹកនៅក្នុងខ្យល់ ឬបរិយាកាស តើយើងមិនអាចមើលឃើញ ព្រោះវាជាចំហាយទឹក។ ទឹកនៅក្នុងខ្យល់ប្រែប្រួលដោយសារសីតុណ្ហភាព។

# កិច្ចតែងការបង្រៀន

គោលដៅ: គរុសិស្ស១៧នាក់
មេរៀនថ្នាក់ទី១០ថ្មី
មេរៀន: ខ្យល់មូសុង (៣ពេល)
.ម៉ោងទី១ ចរន្តខ្យល់ ឬ ខ្យល់បក់
.ម៉ោងទី២ ខ្យល់បក់ប្រចាំទី និងខ្យល់មូសុង
.ម៉ោងទី៣ ទិសខ្យល់បក់ (រយៈពេល ๑0នាទី)

វត្ថុបំណងមេរៀន សិស្ស
.ដឹងពីចរន្តខ្យល់បក់ ឬខ្យល់បក់
.ស្គាល់ពីលក្ខណៈខ្យល់បក់ប្រចាំទី និងខ្យល់បក់តាមតំបន់
.ប្រៀបធៀបរវាងខ្យល់ជំនោរសមុទ្រនិងខ្យល់ជំនោរទ្វីប
.ពន្យល់បង្ហាញពីទិសខ្យល់បក់
.ស្គាល់ពីសារៈប្រយោជន៍ខ្យល់បក់

**១. វត្ថុបំណងមេរៀនរយៈពេល១ម៉ោង (ម៉ោងទី៣)**
**ចំណេះដឹង**
.ពន្យល់ទិសខ្យល់បានត្រឹមត្រូវតាមរយៈការអនុវត្តជាក់ស្តែងនៅទីធ្លាសាលា
**ជំនាញ**
.ទទួលបានជំនាញអនុវត្តរកទិសខ្យល់បក់បានច្បាស់លាស់តាមការណែនាំរបស់គ្រូ
**អភិវឌ្ឍបុគ្គលិកលក្ខណៈ**
.យកចិត្តទុកដាក់លើធាតុអាកាសតាមតំបន់ ជាពិសេសលើដំណើរទិសខ្យល់បក់ប្រចាំថ្ងៃ

**២. សម្ភារៈ ៖**
. ប្លង់ផែនទីវិទ្យាស្ថាន ក្រដាសក្រាស ចង្កឹះឫស្សី ត្រីវិស័យ ស្កុតបិទ ម្ជុលក្បាលធំ ម្ជុលបារាំង ក្រដាសកិច្ចការ កន្ត្រៃតូច រូបភាពខ្យល់មូសុងប្រាំង វស្សា

3. **ដំណើរការបង្រៀន ៖**

| សកម្មភាពគ្រូ | ខ្លឹមសារ | សកម្មភាពសិស្ស |
|---|---|---|
| . គ្រូត្រួតពិនិត្យអវត្តមាន សណ្តាប់ធ្នាប់ថ្នាក់រៀន<br>. រំលឹកមេរៀន | **ជំហ៊ានទី១** (0.៥នាទី)<br>រដ្ឋបាលថ្នាក់រៀន | .តំណាងសិស្សរាយការណ៍ |

| | | |
|---|---|---|
| | **ជំហានទី២** (10នាទី) | |
| .បង្ហាញរូបភាព<br>ខ្យល់មូសុង<br>ប្រាំងវស្សា | <br><br>ក. មូសុងប្រាំង   ខ. មូសុងវស្សា | . ពិនិត្យមើលរូបភាពដោយ  យកចិត្តទុកដាក់ |
| .តើក្នុងរូបភាពនេះ  ប្រទេសកម្ពុជាស្ថិតនៅឯណា? ហើយ រូបភាពនេះ បង្ហាញពីអ្វី?<br><br>.បើខ្យល់បក់មកពីទិសនិរតីឆ្ពោះ ទៅទិសឥសាន្ត គេហៅខ្យល់នោះ ឈ្មោះអ្វី?<br><br>. ចែកសន្លឹកកិច្ចការ<br><br>. គូរទិសទាំង៨លើក្តារខៀន<br>. ចូរដាក់ឈ្មោះទិសទាំង៨ | រដូវទាំង២ប្រចាំឆ្នាំ នៅប្រទេសកម្ពុជា។<br>បញ្ជាក់ពីឈ្មោះទិសខ្យល់បក់<br><br><br>.យល់ច្បាស់ពីទិសដែលនៅ<br>ជុំវិញខ្លួន ជាមួយនឹងទិសនៅ លើផែនទី  ផ្នែកខាងលើគឺខាងជើង ខាងស្តាំគឺខាងកើត | .រូបភាពនេះបង្ហាញពីទិសខ្យល់បក់នៅរដូវប្រាំងនិងវស្សា។ប្រ ទេសកម្ពុជាខ្យល់បក់មកពីទិស និរតីនៅរដូវវស្សាខ្យល់បក់មកពីទិសឥសាន្តនៅរដូវប្រាំង។<br>.បើខ្យល់បក់មកពីទិសនិរតី ឆ្ពោះ ទៅទិសឥសាន្ត គេចឈ្មោះថា ខ្យល់និរតី។<br><br>.សសេរឈ្មោះទិស៤ ជើង  ត្បូង  លិច  កើត  បន្ទាប់មក ទិស៤ទៀតគឺ អគ្នេយ៍  និរតី  ពាយ័ព្យ និងឥសាន្ត។ |
| សំណួរគន្លឹះ៖ **តើខ្យល់បក់មកវិទ្យាស្ថាននេះ បក់មកពីទិសដូចគ្នា ឬទេ?** | | |
| . តើខ្យល់បក់នៅទីនេះ មកពីទិសដូចគ្នា ឬខុសគ្នា?<br>.តើយើងអាចដឹងទិសខ្យល់បាន ដោយរបៀបណា?<br><br>.ប្រាប់ពីឧបករណ៍ងាយៗ<br>មើលទិសខ្យល់<br>.ចូរបង្កើតទិសខ្យល់និរតី<br>.ចូរបង្កើតទិសខ្យល់ទិសទាំង៨ | **ជំហានទី៣** (60នាទី)<br>**មេរៀន ទិសខ្យល់បក់**<br>.ទិសខ្យល់មកកាន់កន្លែងណាមួយ អាចដូចគ្នា ឬខុសគ្នាអាស្រ័យលើ កន្លែងនោះមានផលរំខានពីអ្វីៗដែលនៅជុំវិញ<br>.អនុវត្តនៅក្នុងថ្នាក់ពីរបៀបប្រើ ឧបករណ៍មើលទិសខ្យល់<br><br> | . ខ្យល់បក់មកទីនេះ មកពីទិស ខុសគ្នា / ដូចគ្នា<br>. យើងអាចដឹងទិសខ្យល់បាន ដោយប្រើម្រាមដៃ  ពិនិត្យទង់ជាតិ បាចអង្កាម…<br>.សាកល្បងប្រើឧបករណ៍មើល ទិសខ្យល់<br>.ពិនិត្យមើលឧបករណ៍ស្ទង់ខ្យល់ ខ្យល់បក់ឆ្ពោះទៅទិស ផ្ទុយនឹងកង្ហារ |

| | | |
|---|---|---|
| **សូមចាប់ផ្តើម ពិនិត្យមើលទិសខ្យល់បក់ នៅក្នុងនិងនៅជុំវិញវិទ្យាស្ថាន** | | |
| .ផ្តល់សម្ភារៈឲសិស្សទាំង៧ក្រុម .ណែនាំពីរចំណុចសង្កេតដោយ ប្រើប្លង់វិទ្យាស្ថាន<br>.ណែនាំឲរៀបចំឧបករណ៍ស្ទង់ទិសខ្យល់ និងចុះអនុវត្តតាម ទីតាំងដែលបានកំណត់<br>.ចុះសម្របសម្រួលតាមក្រុម<br><br>.ចូរផ្តល់ចម្លើយតាមលទ្ធផលរកឃើញ | . ចេះរៀបចំបង្កើតឧបករណ៍ងាយៗសម្រាប់ស្ទង់ទិសខ្យល់<br>. យល់ពីរបៀបពិនិត្យទិសខ្យល់<br>.ស្វែងយល់ពីភាពខុសគ្នានៃទិសខ្យល់ ដែលគេបានរកឃើញ | .ទទួលយកសម្ភារៈ និងស្តាប់ តាមការណែនាំ<br>.រៀបចំបង្កើតឧបករណ៍សម្រាប់ស្ទង់ទិសខ្យល់<br>.ចុះទៅតាមទីតាំងសង្កេត<br>. ពិនិត្យមើលទិសខ្យល់<br>.កត់ត្រាលទ្ធផលក្នុងសន្លឹកកិច្ចការ (សម្រេចយកទិសខ្យល់ បក់ជាមធ្យម ក្នុងរយៈពេល១នាទី)<br>.បង្ហាញចម្លើយលើក្តារខៀន |
| ១.តើឧបករណ៍ស្ទង់ទិសខ្យល់នេះ មានប្រសិទ្ធភាពសម្រាប់សង្កេត ទិសខ្យល់ដែរឬទេ?<br>២.តើមានការលំបាកអ្វីខ្លះពេល សង្កេតទិសខ្យល់?<br>៣.ពេលទទួលលទ្ធផលសង្កេតហើយ តើអ្នកអាចឆ្លើយបានដូចម្តេច?<br><br>.សរុបលទ្ធផលរបស់សិស្ស និង ពន្យល់បញ្ជាក់បន្ថែមពីទិស១៦ /ឧបករណ៍ស្ទង់ទិសខ្យល់ សង្ខេបខ្លឹមសារលើក្តារខៀន។ | **ជំហ៊ានទី៤ (13នាទី)**<br>**ពង្រឹងចំណេះដឹង**<br><br>ទិសខ្យល់ខុសគ្នាអាស្រ័យទីតាំងសង្កេតដូចជានៅជិតអគារ អាចខុសគ្នាពីកន្លែងដែលនៅ ឆ្ងាយពីអគារ បើទីតាំងជាទីវាលគ្មានការរំខាននោះទិសខ្យល់គឺដូចគ្នា។ | .ឧបករណ៍ស្ទង់ទិសខ្យល់នេះមានប្រសិទ្ធភាពអាចដឹង បានថាខ្យល់បក់មកពីទិសណាឆ្ពោះទៅទិសណា<br>. ទីតាំងខ្លះពិបាកសង្កេត ស្ទប់ខ្យល់ ចរាចរណ៍អ៊ូអរ ខ្សែបង្ហាញទិសមិន ទៀងទាត់<br>. លទ្ធផលបង្ហាញថា ទិសខ្យល់បក់ ដែលបក់វិទ្យាស្ថាននេះមិនដូចគ្នាទេ អាចមកពីទីតាំងសង្កេតនៅជិតអគារ ឬដើមឈើ។<br><br>.បំពេញបញ្ចប់ចម្លើយ |
| .ចូរយកចិត្តទុកដាក់លើការសង្កេតទិសខ្យល់ប្រចាំថ្ងៃតាមការសង្កេត ដងទង់ជាតិ ហើយកត់ត្រាទុក<br>.តើយើងបានសិក្សាពីអ្វីថ្ងៃនេះ?<br>.ចូរបង្ហាញពីចំណាប់អារម្មណ៍អ្នក<br>.តើមានអ្វីដែលមិនទាន់យល់?<br>.តើចង់ចេះអ្វីទៀតថ្ងៃក្រោយ? | **ជំហ៊ានទី៥ (7នាទី)**<br>**បណ្តាំផ្ញើរ កិច្ចការផ្ទះ**<br>ស្វែងយល់<br>.ចំណាប់អារម្មណ៍ របស់សិស្ស .អ្វីដែលទទួលបាន<br>.អ្វីដែលមិនទាន់យល់ច្បាស់ បណ្តុះស្មារតីឲចេះស្វ័យសិក្សា | .ស្តាប់តាមការណែនាំ<br>.យកទៅអនុវត្តនៅផ្ទះ |

**សន្លឹកកិច្ចការ** ចំនួនសិស្សនៅក្នុងថ្នាក់............................. ឈ្មោះ.........................................

ខ្យល់និរតី?

តើខ្យល់បក់មកវិទ្យាស្ថាននេះ បក់មកពីទិសដូចគ្នា ឬទេ?

..........................................................................................
..........................................................................................
..........................................................................................
..........................................................................................
..........................................................................................
.......................................................................................... ៨ទិស



**សូមចាប់ផ្តើម ពិនិត្យមើលទិសខ្យល់បក់ នៅក្នុងនិងនៅជុំវិញវិទ្យាស្ថាន**

ថ្ងៃទី.............ខែ...............ឆ្នាំ២០១០ ចាប់ផ្តើមម៉ោង...........នាទី.................ដល់ម៉ោង................នាទី...............
ធាតុអាកាស................................. បរិមាណពពក...................................សីតុណ្ហភាព......................................

<table>
<tr><td>ចំនួនចំណុចសង្កេត.............................<br>.....................................................................</td><td rowspan="2">
</td></tr>
<tr><td>ទិសខ្យល់...................................................<br>.....................................................................</td></tr>
</table>

ចំណុចសង្កេតទី២

<table>
<tr><td>ចំនួនចំណុចសង្កេត.............................<br>.....................................................................</td><td rowspan="2">

វិធីបង្កើតឧបករណ៍ស្ទង់ទិសខ្យល់

.រៀបចំសម្ភារៈ ខ្សែ ម្ជុល ចង្កឹះឫស្សី ក្រដាសរឹង ត្រីវិស័យ<br>. កំណត់ទិសទាំង៨ឲបានត្រឹមត្រូវ ជើង ត្បូង លិច កើត និរតី អគ្នេយ៍ និរតី ពាយ័ព្យ និងឥសាន្ត<br>.វិធីសិក្សាសង្កេត: ដាក់ឧបករណ៍ស្ទង់ទិសខ្យល់លើដី និងឈរឲឆ្ងាយ ហើយកំណត់ទិសជាមធ្យមក្នុងរយៈពេលសង្កេត១នាទី ពិនិត្យចំណុចសង្កេត នៅឆ្ងាយ/ជិត អគារ/ដើមឈើរ ដែរឬទេ។</td></tr>
<tr><td>ទិសខ្យល់...................................................<br>.....................................................................</td></tr>
</table>

សង្កេតនៅថ្ងៃទី.........ខែ..................ឆ្នាំ..............ធាតុអាកាស..........................................................

⊗ ⊗ C D E F G H I J ⊗ ⊗ ⊗

N O P Q R S T U V W X Y Z

⊗




<u>សន្និដ្ឋាន</u> ឧទាហរណ៍ ខ្យល់ឥសាន្ត

១.តើឧបករណ៍ស្ទង់ទិសខ្យល់នេះមានប្រសិទ្ធភាពសម្រាប់សង្កេតទិសខ្យល់ដែរឬទេ?..........................................
..................................................................................................................................................................
.................................................................................................................................................................. ២. តើមានការលំបាកអ្វីខ្លះពេលសង្កេតទិសខ្យល់?.......................................................................................
........................................................................................................................................................................
.....................................................................................................................................

៣.ពេលទទួលលទ្ធផលសង្កេតហើយ តើអ្នកអាចឆ្លើយបានដូចម្ដេច?..................................................................
..................................................................................................................................................................
..................................................................................................................................................................

# កំណត់ត្រាទិសខ្យល់

| កាលបរិច្ឆេទ | | ម៉ោង | | ទិសខ្យល់ | | ធាតុអាកាស | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

# ម្លប់ក្តារខៀន

# ទិសខ្យល់បក់




ចូរបំពេញចម្លើយ




ក. មូសុងប្រាំង    ខ. មូសុងវស្សា



ប្រាំង

ឥសាន្ត ឆ្ពោះទៅនិរតី ខ្យល់ឥសាន្ត



វស្សា

និរតី ឆ្ពោះទៅឥសាន្ត ខ្យល់និរតី

សំណួរគន្លឹះ៖ **តើខ្យល់បក់មកវិទ្យាស្ថាននេះ បក់មកពីទិសដូចគ្នា ឬទេ?**

.ម្រាមដៃ . ទង់ជាតិ . ដើមឈើ
.ស្បៃក . បាចអង្កាម . ឧបករណ៍




**សូមចាប់ផ្តើម ពិនិត្យមើលទិសខ្យល់បក់ នៅក្នុងនិង នៅជុំវិញវិទ្យាស្ថាននេះ**




## សន្និដ្ឋាន

.

## ចែកក្រុមតាមទីតាំង

| | | | |
|---|---|---|---|
| ក្រុមទី១៖ | D | E | F |
| ក្រុមទី2៖ | Z | G | T |
| ក្រុមទី3៖ | | | |
| ក្រុមទី4៖ | Y | X | |
| ក្រុមទី5៖ | U | V | |
| ក្រុមទី6៖ | C | N | |
| ក្រុមទី7៖ | S | Q | R |

# ២.

# កិច្ចតែងការបង្រៀនគម្រូ

# នៅតាម

# មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ

# កិច្ចតែងការបង្រៀន

មេរៀនៈ ចំណាំងបែបនៃពន្លឺ
ប្រធានបទៈ ពិសោធន៍ចំណាំងបែបនៃពន្លឺ
រយៈពេលៈ ១ម៉ោង

I– វត្ថុបំណង

– ប្រាប់ពីបាតុភូតចំណាំងបែរនៃពន្លឺ កាលណាកាំពន្លឺឆ្លងកាត់មជ្ឈដ្ឋានថ្លាពីរ ដែលមានសន្ទស្សន៍ខុសគ្នាបានត្រឹមត្រូវតាមរយៈការពិសោធ។
– គូសដំណាលកាំពន្លឺបានត្រឹមត្រូវតាមរយៈការពិសោធ។
– សិស្សដឹងពីស្ថានភាពជាក់ស្តែងនៅក្នុងជីវភាពរស់នៅក្នុងការមើលវត្ថុឆ្លងកាត់ខ្យល់ កែវ ទឹក........។

II– សម្ភារពិសោធន៍

ម្ទូលបារាំង បន្ទះកែវថ្លាស្មើសាច់រាងជាប្រលេពីប៉ែតកែង ក្រដាសរ៉ាម ក្រាដាសឡាំងមី បន្ទាត់វែង ស្កុត និង ដៃខ្មៅចុងស្រួច។

III– សកម្មភាពបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារ | សកម្មភាពសិស្ស |
|---|---|---|
| ពិនិត្យវត្តមានសិស្ស និងអនាម័យ | ជំហានទី១ៈ **រដ្ឋបាលថ្នាក់**<br>ពិនិត្យសណ្តាប់ធ្នាប់ អនាម័យ និងវត្តមានសិស្ស | សិស្សចូលរួម និង រាយការណ៍ |
| ក្នុងមជ្ឈដ្ឋានថ្លា និងស្មើសាច់ តើពន្លឺដាលយ៉ាងដូចម្តេច? | ជំហានទី២ៈ **រំលឹកមេរៀនចាស់** | ពន្លឺដាលតាមទិសជាខ្សែត្រង់ ឬ ជាបន្ទាត់ត្រង់ |
| ដំណើរការពិសោធ<br><br>ឥឡូវសូមសង្កេតមើលដុំលោហៈក្នុងផើងដែក<br><br><u>បង្ហាញបាតុភូត</u> | ជំហានទីៈ ៣<br>**ពិសោធចំណាំងបែរនៃពន្លឺ**<br><br><u>ផើងគ្មានទឹក</u> <u>ផើងមានទឹក</u> | សិស្សសង្កេតបាតុភូតនោះ ដោយយកចិត្តទុកដាក់ |

| | | |
|---|---|---|
| -ហេតុអ្វីបានជាយើងអាចមើលឃើញដុំលោហៈនៅក្នុងផើងដែលមានទឹក?<br><br><br><br>សំណួរគន្លឹះ<br><br>-ប្រសិនបើកាំពន្លឺជាលពីខ្យល់ចូលបន្ទះកែវតើកើតមាននូវបណ្តូរទិសនៃកាំពន្លឺដែរឬទេ?<br>ចូរគូសនូវដំណាលនៃកាំពន្លឺនោះ? | -បានជាយើងអាចមើលឃើញដុំលោហៈនៅក្នុងផើងដែលមានទឹក ព្រោះវាមានចំណាំងបែរនៃពន្លឺដែលចេញពីវត្ថុ។<br><br><br><br>-កាលណាកាំពន្លឺជាលពីខ្យល់ចូលបន្ទះកែវមាននូវបណ្តូរទិសនៃកាំពន្លឺត្រង់ផ្ទៃញែកនៃមជ្ឈដ្ឋានទាំងពីរ។<br><br> | -ផើងដែកដែលគ្មានទឹកយើងមើលមិនឃើញដុំលោហៈ។<br>-ផើងដែកដែលមានទឹកយើងមើលឃើញដុំលោហៈ ព្រោះមានចំណាំបែរនៃពន្លឺ។<br><br><br>-ពិភាក្សា និងសរសេរចម្លើយស្មានទុកជាមុន។<br>. មានបណ្តូរទិសនៃកាំពន្លឺ<br>. រក្សាទិសជាបន្ទាត់ត្រង់<br>-សិស្សគូសតាមគំនិតផ្ទាល់ខ្លួន<br> |
| . ចែកសិស្សតាមក្រុម<br>. ចែកសន្លឹកកិច្ចការ<br>. ដំណើរការពិសោធ<br>-ពន្យល់ដំណើរការពិសោធដោយបង្ហាញនូវឧបករណ៍ជាក់ស្តែង<br>. បិតក្រដាសរ៉ាមលើក្រដាសឡាំង។<br>. បិតកែវអោជាប់លើក្រដាសរ៉ាម រួចគូសបន្ទាត់ស្រប និងកែវ។<br>. ដោតម្ជុលលើបន្ទាត់ស្រប និងកែវ។<br><br>. ដោតម្ជុលរួច ដកកែវចេញរួច | -កាលណាពន្លឺជាលពីខ្យល់ចូលបន្ទះកែវ កើតមាននូវបណ្តូរទិសនៃកាំពន្លឺត្រង់ផ្ទៃញែកនៃមជ្ឈដ្ឋានទាំងពីរ ដែលជាបាតុភូតចំណាំងបែរនៃពន្លឺ។ | -សិស្សស្តាប់ហើយ សង្កេតដោយយកចិត្តទុកដាក់ រួចអានសន្លឹកកិច្ចការដែលគ្រូអោយ។<br><br><br><br>-តំណាងក្រុមឡើងសន្និដ្ឋានភ្ជាប់ |

| | | |
|---|---|---|
| គូសខ្សែកែវ និងបន្ទាត់ស្រប។<br>-ប្រមូលលទ្ធផលបិតលើក្តារខៀន រួចធ្វើការសន្និដ្ឋាន ដោយតំណាងក្រុមនីមួយៗ។ |  | មកជាមួយនូវរូបភាព។ |
| -តើកើតមាននូវបាតុភូតអ្វីនៅពេលដែលពន្លឺដាលពីមជ្ឈដ្ឋានថ្លាមួយទៅមជ្ឈដ្ឋានថ្លាមួយទៀត ហើយមានសន្ទស្សន៍ខុសគ្នា? | ជំហានទី៤: **ពង្រឹងចំណេះដឹង** | -ពេលកាំពន្លឺដាលពីមជ្ឈដ្ឋានថ្លាមួយទៅមជ្ឈដ្ឋានថ្លាមួយទៀត ដែលមានសន្ទស្សន៍ខុសគ្នានោះ កើតមាននូវបណ្តូរទិសនៃកាំពន្លឺ ដែលជាបាតុភូតចំណាំងបែរនៃពន្លឺ។ |
| -ពេលប្អូនធ្វើដំណើរទៅផ្ទះវិញ សូមមើលមេរៀនចំណាំងបែរនៃពន្លឺបន្ថែមទៀត។ | ជំហានទី៥: **បណ្តាំផ្ញើ** | -សិស្សអនុវត្តតាម |

## សន្លឹកកិច្ចការ

សំណួរគន្លឹះ

១. ប្រសិនបើកាំពន្លឺដាលពីខ្យល់មកចូលបន្ទះកែវ តើកើតមាននូវបណ្តូរទិសនៃកាំពន្លឺដែរឬទេ?

២. ចូលគូសនូវដំណាលនៃកាំពន្លឺនោះ។

<u>ការបង្កើតសម្មតិកម្ម:</u> (ទស្សន៍ទាយ ប៉ាន់ស្មាន)

១.

…………………………………………………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………

២.

<u>ពិសោធន៍:</u>

សម្ភារៈ ម្ជុលបារាំង បន្ទះកែវថ្លាស្មើសាច់រាងជាប្រលេពីប៉ែតកែង ក្រដាសរ៉ាម A4 ក្រដាសឡាំងមី បន្ទាត់វែង ស្កុត និងដៃខ្មៅចុងស្រួច។

ដំណើរការពិសោធ

ក. បិតក្រដាសរ៉ាមលើទម្រក្រដាសឡាំងមី និងបិតស្កុត។

ខ. ដាក់កែវថ្លារាងប្រលេពីប៉ែតកែងអោយចំកណ្តាលក្រដាសរ៉ាម ហើយបិតជាប់ និងក្រដាសរ៉ាមរួច គូសបន្ទាត់ស្របពីរតាមបណ្តោយបាតកែវ AB និងCD។

គ. ដោតម្ជុលទី១ ត្រង់ចំណុច O លើបន្ទាត់ AB អោយជិតកែវ ហើយកែង និងប្លង់ក្រដាស។

ឃ. ដោយម្ជុលទី២ អោយរត់ត្រង់គ្នារាងបញ្ឆិតពីក្រោយម្ជុលទី១ ត្រង់ចំណុច $P_1$ ដោយបង្អើតបានមុំស្រួចជាមួយបន្ទាត់ AB។

ង. រកទីតាំងនៃម្ជុលទី៣ ដែលស្ថិតនៅលើបន្ទាត់ CD ដោយត្រង់ចំណុច $R_1$ លៃយ៉ាងណាអោយម្ជុលទី៣ រត់ត្រង់គ្នាជាមួយម្ជុលទី១ និងទី២ មើលក្នុងមុខកាត់កែវ។

ច. បន្ទាប់មកដោតម្ជុលទី៤ នៅខាងមុខម្ជុលទី៣ ត្រង់ចំណុច $R_2$ ដែលអាចអោយមើលឃើញថាម្ជុលទាំង៤ រត់ត្រង់គ្នា។




ឆ. ប្តូរទីតាំងម្ជុលទី២ និងធ្វើដូចលំនាំមុនរកទីតាំងម្ជុលទី៣ និងទី៤។ ធ្វើលំនាំនេះអោយបានពីដងបន្តបន្ទាប់គ្នា។

ជ. យកកែវថ្លាចេញ រួចគូសខ្សែកែង NN′ ត្រង់ចំណុច O អោយកែងនិងបន្ទាត់ AB និងCD ដោយប្រើបន្ទាត់កែងរួចគូសភ្ជាប់រវាងចំណុចម្ជុលទី២ ទី១ ទី៣ និងទី៤ (ចំណុច $P_1$, O, $R_1$, និង $R_2$) អោយជាប់គ្នា ធ្វើរបៀបនេះដដែលៗដោយយកចំណុច O ជារួម។

<u>លទ្ធផល:</u>

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................។

<u>សន្និដ្ឋាន:</u>

..........................................................................................................................................................

..........................................................................................................................................................។

## យោបល់ និងសំណូមពរ

ចំណុចល្អ
- គ្រូបានធ្វើពិសោ ធន៍ដោយចែកសម្ភារៈឲ្យគ្រប់ក្រុមធ្វើរៀងៗខ្លួន ដោយប្រុងប្រយ័ត្ន កុំឲ្យស្អៀង
- សិស្សសកម្មក្នុងការចូលរួមធ្វើពិសោធន៍គ្រប់ៗគ្នា ។
- គ្រូបានដើរមើលគ្រប់ក្រុម និងជួយកែតម្រូវ ដើម្បីរិះរកចម្លើយត្រឹមត្រូវ
- គ្រូឲ្យសិស្សគ្រប់ក្រុមស្រង់លទ្ធផលដែលរកឃើញឡើងក្តារខៀនសរសេរ
គូររូបលើក្តារខៀន និងបន្ទាប់មកសិស្សធ្វើការសន្និដ្ឋានទូទៅដោយខ្លួនឯងឡើង ក្តារខៀន
- ផ្តើមបញ្ហាបានល្អដែលសិស្សអាចរកបាន
- ខ្លឹមសារមេរៀនងាយ
- តាមលំនាំវិទ្យាសាស្ត្រ
- សម្រេចវត្ថុបំណងមេរៀន
- សិស្សមានសកម្មភាពច្រើន
- អនុវត្តតាមជំហាននៃការរៀនតាមការរិះរក
- សិស្សបានអនុវត្តផ្ទាល់តាមការពិសោធន៍
- មានទំនាក់ទំនងល្អរវាងគោលបំណងនិងលទ្ធផលពិសោធន៍
- បានផ្តល់ឱកាសនៃការសិក្សាដល់បានពេញលេញ
- គ្រូណែនាំសំនួរបំផុស
- គ្រូបង្កើតសំនួរគន្លឹះខ្លួនឯង
- គ្រូព្យាយាមជួយជម្រុញឲ្យសិស្សបង្កើតសម្មតិកម្ម និងទុកឱកាសឲ្យសិស្សគិត បានច្រើន (ប៉ុន្តែ ដោយសារតែចំណេះដឹងរបស់សិស្សនៅមានកម្រិតធ្វើឲ្យសិស្ស មិនអាចបង្កើតសម្មតិកម្មបានល្អ ។
- បង្រៀនតាមជំហានវិទ្យាសាស្ត្រ
- សិស្សចូលរួមសង្កេត និងពិសោធន៍ជាក់ស្តែង

ចំណុចកែលម្អ
- គ្រូបានឲ្យសិស្សធ្វើពិសោធន៍គ្រប់ក្រុមយ៉ាងសកម្ម និងច្បាស់លាស់ល្អ ។ ប៉ុន្តែពុំ បានកំណត់រយៈពេលដែលដំណើរការនេះឲ្យបានសមស្រប ព្រោះសិស្សខ្លះបាន ធ្វើហើយមុនឡើងបិទ សិស្សឯទៀតមិនទាន់បាន ។
- គ្រូពុំបានកំណត់រយៈពេលឲ្យសិស្សតាមក្រុមឡើងបកស្រាយ ។
- គួរគូររូបភាពនៅលើក្តារខៀនដើម្បីងាយស្រួលមើលកាំចាំងប៉ះនិងការចាំងបែរ
- បង្កើតសង្កេតឲ្យបានគ្រប់ក្រុម
- គ្រូតពិនិត្យការពិសោធន៍សិស្សឲ្យបានគ្រប់ក្រុម
- សិស្សចេះបានតិច
- គ្រូគួរដើរត្រួតពិនិត្យការធ្វើពិសោធន៍តាមក្រុមឲ្យម៉ត់ចត់
- គ្រូគួរឲ្យសរសេរសន្និដ្ឋានពិសោធន៍លើក្តារខៀន
- គួរគូសរូបខ្មៅក្នុងកែវក្រោយពីការធ្វើពិសោធន៍

- គួរបញ្ជាក់ផ្ទៃញែកមជ្ឈដ្ឋានទាំងពីរ
- គួរកាត់បន្ថយពេលវេលានៃការបង្រៀន
- គួរគូរបធំៗលើក្តារខៀនឲ្យសិស្សគ្រប់មើលឃើញ
- មុនរៀនមេរៀនសំណូមពរឲ្យគ្រូវពន្យល់ពាក្យគន្លឹះមួយចំនួនដូចជា «បណ្តូរទិស នៃកាំពន្លឺ, ដំណាល នៃកាំពន្លឺ,កាំពន្លឺដាលជាខ្សែក្រង, ខ្សែតែង , មជ្ឈដ្ឋានថ្លាស្មើ សាច់» ពីព្រោះសិស្សមានចំណេះដឹងតាមទៅលើមេរៀននេះ ។
- បំផុសសំនួរៈ គួរប្រើឲ្យបានច្បាស់ មជ្ឈដ្ឋានថ្លាស្មើសាច់ ឬគួរសួរថា តើមូលហេតុ អ្វីបានជាយើងឃើញវត្ថុទាំងឡាយនៅជុំវិញខ្លួនយើង» ។
- មិនបានឲ្យសិស្សគ្រប់ក្រុមចូលរួមសង្កេតបាតុភូត
- សិស្សមិនបានចូលរួមបង្កើតកំណត់បញ្ហា
- ឱកាសការរៀនរបស់សិស្សពុំសូវបានល្អ
- គ្រូប្រាប់សិស្សធ្វើពិសោធន៍
- លំនាំបញ្ហារួចហើយគួរប្រើពាក្យថាថ្ងៃនេះយើងរៀនមេរៀនថ្មីមួយគឺ...ទើបសរសេរសំនួរគន្លឹះលើក្តារខៀន
- គួរមានបណ្តាំផ្ញើ

# កិច្ចតែងការបង្រៀន

មុខវិជ្ជា  រូបវិទ្យា
ថ្នាក់ទី  ៧
ជំពូកទី២ កម្តៅ
មេរៀនទី១ ការចម្លងកម្តៅ(២ម៉ោង)

I– វត្ថុបំណង

- ចំណេះដឹងៈ  រៀបរាប់ចម្លងកម្តៅនៃអង្គធាតុរឹងតាមរយៈការពិសោធន៍បានត្រឹមត្រូវ
- បំណិនៈ  ពន្យល់ពីការចម្លងកម្តៅនៃអង្គធាតុរឹងតាមរយៈការអនុវត្តក្នុងថ្នាក់បាន ច្បាស់លាស់។
- ឥរិយាបថៈ មានបម្រុងប្រយ័ត្នក្នុងការយកអង្គធាតុរឹងទៅធ្វើជាឧបករណ៍ប្រើប្រាស់ក្នុង ជីវភាពរស់នៅ និងមានបម្រុងប្រយ័ត្នក្នុងការធ្វើពិសោធជាមួយភ្លើងអាចរលាកតាមរយៈអនុវត្តការពិសោធជាក់ស្តែងក្នុងថ្នាក់រៀន។

II– សម្ភារបង្រៀន

- ទៀនធំ ទៀន បន្ទះចម្លងកម្តៅ ដែកកេះ ទឹក ធុងទឹក បន្ទះដែក (ចំរៀកកំប៉ុងទឹកដោះគោ) បន្ទះអាលុយមីញ៉ូម (ចម្រៀកកំប៉ុងស្រាបៀ) បន្ទះទង់ដែង កន្រ្តៃ កំប៉ុងទឹកដោះគោ(កាត់ គូថ) សសៃទង់ដែង ឬស្សី ការបិទក្រដាស ស្មោ ឈើស្ងួត ស្ព៊ីរ៉ូហ្វម។

III– ដំណើកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| . ពិនិត្យអនាម័យ<br>. ពង្រឹងវិន័យ<br>. ពិនិត្យអវត្តមាន<br>. សណ្តាប់ធ្នាប់ | ជំហានទី១<br>(រដ្ឋបាលថ្នាក់)<br>ប្រមូលអារម្មណ៍សិស្ស | . ប្រធានថ្នាក់រាយការណ៍អវត្តមាន |
| . តើប្អូនធ្លាប់យកវែកសម្លធ្វើពីដែកកូរសម្លដែរឬទេ?<br>. តើមានអ្វីកើតឡើងពេលដែលយើងកូរយូរ?<br>. តើប្អូនធ្លាប់យកចង្កឹះធ្វើពីឈើកូរសម្លឬទេ?<br>. តើយ៉ាងដូចម្តេចបើយើងកូរយូរ?<br>. តើអង្គធាតុរឹងមានអ្វីខ្លះ? | ជំហានទី២<br>(រំលឹកមេរៀនចាស់) | . ធ្លាប់<br>. វែកឡើងក្តៅរហើយ រលាកដៃ<br>. ធ្លាប់<br>. ចង្កឹះមិនឡើងក្តៅដល់ដៃទេ<br>. អង្គធាតុរឹងមាន<br>. ដែក (Fe), អាលុយមីញ៉ូម (AL), ទង់ដែង (CU), ស្ពាន់(B)..., ឈើស្ងួត ស្មោ ស្ព៊ីរ៉ូហ្វម... |

<table>
<tr>
<td>ចូរប្អូនទាំងអស់គ្នាចាំទាយមើល តើចំណងជើងមេរៀនរបស់យើងថ្ងៃនេះគឺអ្វី?<br>. ចែកសិស្សជាក្រុម<br>. ចែកសន្លឹកកិច្ចការអោយសិស្ស<br>. ចែកបន្ទះ CU, AL, Fe សិស្សតាមក្រុម<br>. ណែនាំអោយសិស្សដុត<br>• ក្រោយដុត តើប្អូនមានអារម្មណ៍ដូចម្ដេច?<br>• តើល្បឿននៃការក្ដៅរបស់អង្គធាតុទាំង៣ដូចគ្នាឬទេ?<br>• តើមួយណាឆាប់ក្ដៅជាងគេ?<br>I– កំណត់បញ្ហា<br><br>. សំយោគសំណួរតាមក្រុម</td>
<td>ជំហានទី៣<br>(មេរៀនប្រចាំថ្ងៃ)<br><br>. ការចម្លងកម្ដៅ និងលក្ខណ:នៃការចម្លងកម្ដៅ<br><br>សំណួរគន្លឹះ:</td>
<td>. ចូលតាមក្រុម<br>. ទទួលសន្លឹកកិច្ចការ<br>. ទទួលបន្ទះ CU, AL, Fe តាមក្រុម<br>អនុវត្តតាមការណែនាំ<br>. ក្រុមនីមួយៗពិភាក្សាលើសំណួរ<br>. ក្ដៅមកដល់ដៃ<br>. ល្បឿននៃការក្ដៅរបស់អង្គធាតុទាំង៣មិនដូចគ្នាទេ។<br><br>. ឆាប់ក្ដៅជាងគេគឺ .... និងបន្ទាប់គឺ..... តាមការយល់ឃើញរបស់សិស្ស</td>
</tr>
<tr>
<td colspan="3">តើការចម្លងកម្ដៅនៃអង្គធាតុរឹងដូចគ្នាដែរឬទេ?</td>
</tr>
<tr>
<td>. អោយសិស្សឡើងបកស្រាយពីជម្រើសរបស់គេរៀងៗខ្លួន<br>១). ចែកសម្ភារពិសោធន៍<br><br>២). ណែនាំរបៀបពិសោធន៍<br>II– បង្កើតសម្មតិកម្ម<br>អោយសិស្សទាយចម្លើយមុនពេលពិសោធន៍<br>. តើទៀននៅលើបន្ទះលោហៈណាដួលមុនគេ និងបន្តបន្ទាប់?<br>III– ពិសោធន៍<br>. អោយសិស្សធ្វើពិសោធន៍ រួចបំពេញតារាង<br>. ដើរត្រួតពិនិត្យ មើលការធ្វើពិសោធន៍<br>IV– ស្រង់លទ្ធផល</td>
<td>. ជម្រើសរបស់សិស្សតាមការយល់ឃើញ<br><br><br><br></td>
<td>. បកស្រាយតាមការយល់ឃើញ<br><br>. ក្រុមនីមួយៗទទួលសម្ភារ:ពិសោធន៍<br>. ស្ដាប់របៀបពិសោធន៍<br><br>. ឆ្លើយតាមការយល់ឃើញ<br>តារាងលទ្ធផលសិស្ស<br>
<table>
<tr><td>អ.ធ រឹង</td><td colspan="3">ក្រុម១</td><td colspan="3">ក្រុម២</td></tr>
<tr><td></td><td>១</td><td>២</td><td>៣</td><td>១</td><td>២</td><td>៣</td></tr>
<tr><td>Cu</td><td></td><td></td><td></td><td></td><td></td><td></td></tr>
<tr><td>Al</td><td></td><td></td><td></td><td></td><td></td><td></td></tr>
<tr><td>Fe</td><td></td><td></td><td></td><td></td><td></td><td></td></tr>
<tr><td>B</td><td></td><td></td><td></td><td></td><td></td><td></td></tr>
</table></td>
</tr>
</table>

<table>
<tr>
<td>. សំយោគលទ្ធផលសិស្ស<br>V- សន្និដ្ឋាន<br>. សំយោគការសន្និដ្ឋានរបស់សិស្ស<br><br>. ចែកបន្ទះ ស្មោ ឈើស្ងួត ស្ប៉ៃហ្វម អោយសិស្សតាមក្រុម<br>. ណែនាំអោយសិស្សដុត<br>. ក្រោយពីដុត តើប្អូនមានអារម្មណ៍ដូចម្តេច?<br>. ចូរប្អូនប្រៀបធៀបអង្គធាតុរឹងដែលដុតឥឡូវនេះ និងដុតលើមុន តើខុសគ្នា ឬដូចគ្នា?<br>. តើប្អូនអាចដាក់ឈ្មោះអង្គធាតុរឹងដែលបានពិសោធនទាំងពីលើបានឬទេ?<br>. តើអង្គធាតុរឹងដែលបានពិសោធលើកទី១ វាយ៉ាងដូចម្តេចចំពោះកម្តៅ? ហើយអង្គធាតុរឹងដែលបានពិសោធលើកទី២វាយ៉ាងដូចម្តេច ចំពោះកម្តៅ?</td>
<td>
<table>
<tr><td>អ.ធ រឹង</td><td colspan="3">ក្រុម១</td><td colspan="3">ក្រុម២</td></tr>
<tr><td></td><td>១</td><td>២</td><td>៣</td><td>១</td><td>២</td><td>៣</td></tr>
<tr><td>Cu</td><td>១</td><td>១</td><td>១</td><td>១</td><td>១</td><td>១</td></tr>
<tr><td>Al</td><td>២</td><td>២</td><td>២</td><td>២</td><td>២</td><td>២</td></tr>
<tr><td>Fe</td><td>៣</td><td>៣</td><td>៣</td><td>៣</td><td>៣</td><td>៣</td></tr>
<tr><td>B</td><td>៤</td><td>៤</td><td>៤</td><td>៤</td><td>៤</td><td>៤</td></tr>
</table>
<br>. ទង់ដែងដូលមុនគេ បន្ទាប់មកអាលុយមីញ៉ូម ដែក ស្ពាន់ ដូចនេះ ការចម្លងកម្តៅរបស់អង្គធាតុរឹងមិនដូចគ្នាទេ នៅក្នុងចំណោមអង្គធាតុរឹងខាងលើ ទង់ដែងចម្លងកម្តៅបានល្អជាងគេ<br><br>. អង្គធាតុចម្លងកម្តៅ និងអ៊ីសូឡង់កម្តៅ</td>
<td>. ទង់ដែងដួលមុនគេ បន្ទាប់មកអាលុយមីញ៉ូម ដែក ស្ពាន់ ដូនេះ ការចម្លងកម្តៅរបស់អង្គធាតុរឹងខាងលើទង់ដែងចម្លងកម្តៅ បានល្អជាងគេ។<br>. ទទួលបន្ទះ ស្មោ ឈើស្ងួត ស្ប៉ៃហ្វម តាមក្រុម<br>. អនុវត្តន៍តាមការណែនាំ<br>. តំណាងក្រុមនីមួយៗឡើងឆ្លើយសំណួរ។<br><br>. អង្គធាតុចម្លងកម្តៅ និងអង្គធាតុស្ទើរតែមិនចម្លងកម្តៅ (អ៊ីសូឡង់កម្តៅ)</td>
</tr>
<tr>
<td>. យកសម្ភារៈធ្វើពីឫស្សីភ្ជាប់ជាមួយទង់ដែងដោយប្រើក្រដាស់រុំភ្ជាប់ ដែលគ្រូត្រៀមរួចជាស្រេច ចែកអោយសិស្ស។<br>. អោយសិស្សដុតរួចសង្កេត និងពន្យល់ពីបាតុភូត<br><br>. តើអង្គធាតុចម្លងកម្តៅ និងអ៊ីសូឡង់កម្តៅគេយកទៅប្រើប្រាស់យ៉ាងដូចម្តេចខ្លះក្នុងជីវភាពរស់នៅប្រចាំថ្ងៃ?</td>
<td>ជំហានទី៤<br>(ពង្រឹងចំណេះដឹង)<br><br></td>
<td>. សិស្សដុត និងសង្កេត និងបាតុភូតរួចពន្យល់តាមការយល់ឃើញ។<br>. អង្គធាតុចម្លងកម្តៅគេយកទៅធ្វើជាឆ្នាំងអ៊ុត កំសៀវ ឆ្នាំងបាយ ខ្ទះរឹង អ៊ីសូឡង់កម្តៅគេយកទៅធ្វើទ្រនាប់វា។</td>
</tr>
</table>

| | | |
|---|---|---|
| . ទៅផ្ទះវិញមើលមេរៀនបន្តត្រង់ចំណុច២ និង៣ (ការចម្លងកម្ដៅនៃអង្គធាតុរាវ ការចម្លងកម្ដៅនៃឧស្ម័ន)<br>. ផ្ដល់ដំបូន្មានដល់សិស្ស | ជំហានទី៥ (បណ្ដាំផ្ញើ)<br>. កិច្ចការផ្ទះ<br>. អភិវឌ្ឍបុគ្គលិកលក្ខណៈ | . សិស្សស្ដាប់ និងកត់ត្រា<br>. សិស្សស្ដាប់ដោយយកចិត្តទុកដាក់ |

## សន្លឹកកិច្ចការ

១) លំនាំបញ្ហា

- ក្រោយពីជុតតើប្អូនមានអារម្មណ៍ដូចម្តេច? ព្រោះអ្វី?

---------------------------------------------------------------------------

២) សំណួរគន្លឹះ

---------------------------------------------------------------------------

- តើល្បឿននៃការក្តៅរបស់អង្គធាតុទាំង៣ដូចគ្នាឬទេ? ហើយមួយណាឆាប់ក្តៅជាងគេ និងបន្តបន្ទាប់?

---------------------------------------------------------------------------

៣) ចូរអនុវត្តន៍ការពិសោធខាងក្រោម

- ចម្លើយគិតទុកមុនពេលពិសោធន៍
    - តើទៀននៅលើបន្ទះលោហាណាដួលមុនគេ និងបន្តបន្ទាប់?




---------------------------------------------

---------------------------------------------

---------------------------------------------




៤) ពិសោធន៍ និងស្រង់លទ្ធផល

- ចូរធ្វើពិសោធន៍ រួចបំពេញតារាង

| អ.ធ រឹង | ក្រុម១ | | | ក្រុម២ | | |
|---|---|---|---|---|---|---|
| | ១ | ២ | ៣ | ១ | ២ | ៣ |
| Cu | | | | | | |
| Al | | | | | | |
| Fe | | | | | | |
| B | | | | | | |

៥) សន្និដ្ឋាន

---------------------------------------------------------------------------

---------------------------------------------------------------------------

---------------------------------------------------------------------------

- ចូលដាក់ចំណងជើងមេរៀនថ្ងៃនេះ...........................................................................

# យោបល់ និងសំណូមពរ

ចំណុចល្អ
– ចេះប្រើឧបករណ៍ច្បាស់លាស់ ដើម្បីបំផុសគំនិតសិស្សឲ្យទាញរកសំនួរគន្លឹះ
– ផ្តល់ឱកាសឲ្យសិស្សទាញសម្មតិកម្មពីសំនួរគន្លឹះដោយខ្លួនឯង
– ណែនាំដំណើរការពិសោធន៍បានច្បាស់លាស់
– សិស្សមានសកម្មភាពរស់រវើក ។
– តាមលំដាប់លំដោយនៃជំហាន
– មានលក្ខណៈវិទ្យាសាស្ត្រ
– បានឲ្យសិស្សដាក់ចំណងជើងមេរៀនពិសោធន៍និងសន្និដ្ឋានរួច ។
– ខ្លឹមសារមេរៀនសមស្របនិងចំណេះដឹងរបស់សិស្ស
– បានផ្តល់ឲ្យមានការគិតច្រើន
– សិស្សមានឱកាសរៀនច្រើន
– ឲ្យសិស្សធ្វើការសន្និដ្ឋាន
– ផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែង
– សិស្សព្យាយាមគូសក្រាប
– បង្កើតសម្មតិកម្មបានល្អ
– ដំណើរការពិសោធន៍ប្រព្រឹត្តទៅបានល្អ ហើយប្រើពេលសមរម្យ ។
– សិស្សមានសកម្មភាពពេលរៀន
– គ្រូទាញអារម្មណ៍សិស្សពេលចូលដំណើរការបង្រៀន ។
– ចំណុចចាប់ផ្តើមមានភាពទាក់ទាញ (បរិយាយពីបាតុភូតធម្មជាតិ រួចលើកជា សំនួរពិភាក្សា)
– ណែនាំ+បំរុងប្រយ័តចំពោះការប្រើប្រាស់ឧបករពិសោធន៍
– សិស្សគូរក្រាបពីសីតុណ្ហភាពរបស់លោហៈទាំង ៤ នៅក្នុងរយៈពេលស្មើគ្នា
– ពិសោធន៍ដុតក្រដាសរុំលើលោហៈនិងឈើ ។
– ការប្រើសំនួរមិនសូវច្បាស់លាស់
– ពេលក្រុមសិស្សធ្វើពិសោធន៍ មិនបានលទ្ធផលដូចការគិតទុក ធ្វើឲ្យលោកគ្រូ ខ្វះទំនុកចិត្ត ហើយចាប់ផ្តើមដំណើរការពិសោធន៍ឡើងវិញដោយលោកគ្រូ ធ្វើឲ្យ សិស្សបាត់បង់ឱកាសស្វែងរកលទ្ធផលពិសោធន៍ ។

ចំណុចកែលម្អ
– មិនបានឲ្យសិស្សឡើងសរសេរសេចក្តីសន្និដ្ឋានលើក្តារខៀន
– គួរបន្ថែមសម្មតិកម្មមួយទៀត ដើម្បីឲ្យសិស្សងាយ ព្រោះសម្ភារៈពិសោធន៍មាន
លោហៈ 4 ខុសគ្នា Re, Al, Cu, Bre
– ប្រាប់ឈ្មោះ Ba ខុស
– មិនបានបង្ហាញការបិតទៀន (ឧៈ ត្រង់ ភ្ជាប់ប៉ុន្មានតំណក់......ពីគល់ទៀននីមួយៗ
– មិនសូវចុះដិតដល់តាមក្រុមនីមួយៗ ដោយចុះក្រុមមួយៗច្រើនជាងក្រុមមួយទៀត ។

- មិនគួរឲ្យសិស្សគូសក្រាប
- មិនបានឲ្យសិស្សប្រាប់ហេតុផលត្រង់ ក.ក
- កំនត់និយមន័យឲ្យសិស្សមិនទាន់ត្រឹមត្រូវ
- សួរសិស្សដោយមិនទាន់រៀបចំខ្លួមរួច
- ប្រាប់តាមក្រុមឲ្យទាញមករកត្រឹមត្រូវ
- មិនបានណែនាំឲ្យសិស្សដោតទៀនត្រឹមត្រូវ
- គ្រូសួរដល់សិស្សដូចជាសិស្សពិបាកស្តាប់ (អ/ធ រឹងមានប៉ុន្មាន ?)
- ពិនិត្យមើលការតំឡើងសម្ភារៈរបស់ក្រុមនីមួយៗ ឲ្យបានច្រើនថែមទៀត
- បញ្ជាក់ឲ្យបានច្បាស់ថែមទៀតពីរបៀបសង់ក្រាប
- គួរកុំឆ្លើយលឿនពេកនូវសំនួរដែលគ្រូសយរសិស្ស

# កិច្ចតែងការបង្រៀន

មុខវិជ្ជា: គីមីវិទ្យា ថ្នាក់ទី៩
ជំពូកទី៣: អុកស៊ីត បាស និងអំបិល
ប្រធានបទ: អត្តសញ្ញាណកម្មអាស៊ីត បាស និងណឺតក្នុងសូលុយស្យុងមួយចំនួន (រយៈពេល ១ម៉ោង)

I– វត្ថុបំណង(ក្រោយពីបញ្ចប់មេរៀនសិស្សអាច)

- ចំណេះដឹង: សំគាល់ពណ៌អាស៊ីត បាសនិងណឺតជាមួយអង្គធាតុចង្អុលពណ៌ និងក្រដាស pH តាមរយៈការសង្កេតពិសោធបានត្រឹមត្រូវ។
- បំណិន: ញែកសំគាល់សូលុយស្យុងដែលជាអាស៊ីតបាស ឬណឺតតាមរយៈការអនុវត្តបានច្បាស់លាស់។
- ឥរិយាបថ: មានបំរុងប្រយ័ត្នក្នុងការប្រើប្រាស់សារធាតុដែលមានជាតិអាស៊ីតបាស ឬណឺតតាមរយៈជីវភាពបានកម្រិតខ្ពស់។

II– សម្ភារបង្រៀន និងរៀន

- បំពង់សាកចំនួន ៥២ ទម្របំពង់សាកចំនួន៥ ទឹកសំបកស្រកានាគចំនួន ៥ដប (១០០មល) ពីប៉ែតបន្តក់ចំនួន៥
- ក្រូចឆ្មារ ទឹកក្បុង ថ្នាំដុសធ្មេញសាប៊ូលាងបង្គន់ ម្សៅសូដា ដូង ទឹកខ្មេះ អំបិល ក្រដាស pH និងទឹកម៉ាស៊ីន
- សូដ្យូមអ៊ីដ្រុកស៊ីតកហាប់ $5.10^{-2}$ $mol.L^{-1}$ ចំនួន(២០០មល) អាល់កុល អាស៊ីតស៊ុលផួរិច

III– ដំណើកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| ពិនិត្យ អវត្តមាន អនាម័យ វិន័យ និងសណ្តាប់ធ្នាប់សិស្ស | ជំហានទី១<br>(រដ្ឋបាលថ្នាក់)<br>អវត្តមាន អនាម័យ វិន័យ សណ្តាប់ធ្នាប់ | ប្រធានថ្នាក់<br>ឬតំណាងថ្នាក់ឡើងរាយការណ៍ |
| តើអាស៊ីតមានលក្ខណៈដូចម្តេចខ្លះ?<br><br><br>តើបាសមានលក្ខណៈដូចម្តេចខ្លះ? | ជំហានទី២<br>(រំលឹកមេរៀន) | អាស៊ីតមានលក្ខណៈដូចខាងក្រោម:<br>. មានរសជូរ<br>. ប្តូរពណ៌ក្រដាសត្តណឺសុលពីខៀវទៅក្រហម។<br>. បាសមានលក្ខណៈដូចខាងក្រោម:<br>. មានរសល្វីង |

| | | |
|---|---|---|
| | | . ប្តូរពណ៌ក្រដាសតួណឺសុលពីក្រហមទៅខៀវ។ |
| អោយសិស្សសង្កេតពណ៌របស់សូលុយស្យុងអាស៊ីតស៊ុលផួរិច និងសុដ្យូមអ៊ីដ្រុកស៊ីតពេលចាក់អង្គធាតុចង្អុលពណ៌ចូល។ (ទឹកសំបកស្រកានាគ) | ជំហានទី៣ (មេរៀនថ្មី ឬមេរៀនប្រចាំថ្ងៃ) អាស៊ីត បាស និងណឺត សូមប្អូនបង្ហាញសូលុយស្យុងដែលប្អូនបានយកមកពីផ្ទះ: ទឹកក្រូចឆ្មារ ទឹកក្បុង ទឹកថ្នាំដុសធ្មេញ ទឹកសាប៊ូម្សៅ សាប៊ូលាងបង្គន់ ទឹកម្សៅសូដា ទឹកដូង ទឹកខ្មេះ ទឹកអំបិល និងទឹកម៉ាស៊ីន | . សិស្សសង្កេតពិសោធន៍បង្ហាញ<br>. សិស្សកំណត់បញ្ហា |
| សំណួរគន្លឹះ: តើសូលុយស្យុងណាខ្លះជាបាស? ណាខ្លះជាអាស៊ីត? ហើយណាខ្លះជាណឺត? | | |
| ផ្តល់ឱកាសអោយសិស្សទស្សន៍ទាយ។<br><br>សិស្សបង្កើតប្លង់ពិសោធន៍ | សម្មតិកម្ម<br>. **អាស៊ីតមាន:** ទឹកក្រូចឆ្មារ ទឹកដូង សាប៊ូលាងបង្គន់ ទឹកខ្មេះ។<br>. **បាសមាន:** ទឹកសាប៊ូម្សៅ ទឹកក្បុង ទឹកថ្នាំដុសធ្មេញ ទឹកម្សៅសូដា។<br>. **ណឺតមាន:** ទឹកអំបិល ទឹកម៉ាស៊ីន។<br>***ប្លង់ពិសោធន៍*** | . ទស្សន៍ទាយតាមការយល់ឃើញ<br><br>. គិតពីគម្រោងពិសោធន៍ |




| | | |
|---|---|---|
| អោយសិស្សធ្វើពិសោធន៍ និងបំពេញលទ្ធផលចូលសន្លឹកកិច្ចការ។ | ***លទ្ធផលសង្កេត:***<br>**ពណ៌ក្រហមស្វាយ:** ទឹកក្រូចឆ្មារ ទឹកដូង សាប៊ូលាងបង្គន់ ទឹកខ្មេះ។<br>**ពណ៌បៃតង:** ទឹកសាប៊ូម្សៅ ទឹកក្បុង ទឹកថ្នាំដុសធ្មេញ ទឹកម្សៅសូដា។ | សិស្សធ្វើពិសោធន៍: យកសូលុយស្យុងទាំងអស់ដាក់ក្នុងបំពង់សាកផ្សេងៗ គ្នា រួចចាក់អង្គធាតុចង្អុលពណ៌ទឹកសំបកមង្ឃុត ឬទឹកសំបកស្រកានាគចូលបំពង់សាកទាំងអស់ បន្ទាប់មកសង្កេតក្នុងបំពង់សាកនីមួយៗ ដោយប្រៀប |

<table>
<tr>
<td></td>
<td>មិនប្តូរពណ៌: ទឹកអំបិល ទឹកម៉ាស៊ីន។<br>លទ្ធផលពិភាក្សា:<br>.ទឹកក្រូចឆ្មារ ទឹកដូង សាប៊ូលាងបង្គន់ ទឹកខ្មេះជាអាស៊ីត ព្រោះមានពណ៌ដូចសូលុយស្យុងអាស៊ីត ក្នុងបំពង់សាកស្តង់ដា។<br>. ទឹកសាប៊ូម្សៅទឹកក្បុង ទឹកថ្នាំដុសធ្មេញ ទឹកម្សៅសូដា ជាបាស ព្រោះមានពណ៌ដូចសូលុយស្យុងបាសក្នុងបំពង់សាក ស្តង់ដា។<br>. ទឹកអំបិល ទឹកម៉ាស៊ីន ជាសូលុស្យុងណឺត។</td>
<td>ធៀបជាមួយសូលុស្យុងក្នុងបំពង់សាកស្តង់ដា។</td>
</tr>
<tr>
<td colspan="3">ជំហានទី៤ (សន្និដ្ឋាន)<br><br>តំរៀបលក្ខណៈអាស៊ីតខ្លាំងទៅខ្សោយ: > > > ><br><br>តំរៀបលក្ខណៈបាសខ្លាំងទៅខ្សោយ: > > > ><br><br></td>
</tr>
<tr>
<td>ពេលប្អូនទៅផ្ទះវិញសូមធ្វើពិសោធដូចនេះជាមួយ និងសូលុយស្យុង ទឹកស្ករសរ ទឹកត្រពាំង សាប៊ូកក់សក់ និងទឹកកំបោរ ដើម្បីថាមួយណាជាអាស៊ីត បាស ឬណឺត។</td>
<td>ជំហានទី៥</td>
<td>ទទួលយកបណ្តាំផ្ញើទុកអនុវត្តនៅផ្ទះ។</td>
</tr>
</table>

# សន្លឹកកិច្ចការ

## ប្រធានបទ៖ អត្តសញ្ញាណកម្ម និងចំណាត់ថ្នាក់អាស៊ីត បាស និងណឺត

សង្កេត៖

| | ពណ៌ | | |
|---|---|---|---|
| | ក្រដាសpH | ស្រកានាគ | មង្ឃុត |
| អាស៊ីត | | | |
| បាស | | | |

### សំណួរគន្លឹះ

អាស៊ីតមាន៖........................................................................................................................

បាស៖..................................................................................................................................

### ប្លង់ពិសោធន៍

### ចូរធ្វើពិសោធន៍

| សូលុយស្យុង | ការសង្កេត | | | |
|---|---|---|---|---|
| | ពណ៌&តម្លៃpH | ពណ៌ស្រកានាគ | ពណ៌មង្ឃុត | អាស៊ីត បាស ឬណឺត? |
| ១. | | | | |
| ២. | | | | |
| ៣. | | | | |
| ៤. | | | | |
| ៥. | | | | |
| ៦. | | | | |
| ៧. | | | | |
| ៨. | | | | |
| ៩. | | | | |
| ១០. | | | | |

### ពិភាក្សា និងសន្និដ្ឋាន

ចូរធ្វើចំណាត់ថ្នាក់សូលុយស្យុងខាងលើទៅតាមកម្លាំងអាស៊ីតកើន៖

ចូរធ្វើចំណាត់ថ្នាក់សូលុយស្យុងខាងលើទៅតាមកម្លាំងបាសកើន៖

ចូរតម្រៀបសូលុយស្យុងខាងលើលើអ័ក្ស pH ខាងក្រោម៖

# យោបល់ និង សំណូមពរ

| |
|---|
| ចំណុចល្អ<br>– ពេលសិស្សធ្វើពិសោធន៍យូរដោយមានការពិសោធន៍ច្រើន<br>– សិស្សមានការយល់ អាចធ្វើការពិសោធន៍បានយ៉ាងច្បាស់ល្អ<br>– ផ្ដើមបញ្ហានិងបាតុភូតបានល្អត្រឹមត្រូវ<br>– ទាក់ទាញចម្ងល់សិស្ស និងបង្កើតសំនួរ ដើម្បីឲ្យសិស្សបង្ហាញហេតុផល<br>– សិស្សចេះលៃលកភារកិច្ចរបស់ខ្លួនក្នុងក្រុម<br>– ការរៀបចំរចនាបទមេរៀនបានត្រឹមត្រូវ (សន្លឹកកិច្ចការសំរាប់សិស្ស និងប្រើប្រាស់ប្លង់ក្ដារខៀន)<br>– ដើរតាមដំណើរការវិទ្យាសាស្ត្រ<br>– ណែនាំសិស្សជាមុន<br>– បានរំលឹកមេរៀនរៀនរួច<br>– បង្រៀនតាមជំហានវិទ្យាសាស្ត្រ<br>– សិស្សបានពិភាក្សាគ្នា ធ្វើពិសាធន៍ និងបង្ហាញលទ្ធផល<br>– ធ្វើសេចក្ដីសន្នដ្ឋានពេលបញ្ចប់មេរៀន<br>– ចាប់ផ្ដើមដំណើរការបានល្អ (ណែនាំខ្លួន សួរសុខទុក្ខសិស្ស...)<br>– រំលឹកមេរៀនបានល្អពីលក្ខណៈអាស៊ីតឬបាសឬណឺត<br>– បង្ហាញស្វ ស្តង់ដារនៃអាស៊ីឬបាស<br>– កត់ចំណងជើងដាក់លើក្ដារខៀនតាមលំនាំលំដោយនៃមេរៀនការរិះរក ។<br>– សិស្សធ្វើប្លង់ពិសោធន៍ដោយខ្លួនឯង<br>– សិស្សមានឱកាសក្នុងការអនុវត្តបកស្រាយ<br>– សំយោគលទ្ធរបស់សិស្ស<br>– បង្ហាញបាតុភូតពិសោធន៍<br>– សម្រេចវត្ថុបំណងទាំងគ្រូ និងសិស្ស<br>– សិស្សបានធ្វើពិសោធន៍និងរកចម្លើយដោយខ្លួនឯង<br>– សិស្សមានសកម្មភាពគ្រប់គ្នា<br>– មេរៀននេះល្អដោយជួយគ្នាជាក្រុម (អង្គធាតុចង្អុលពណ៌ច្បាស់)<br>– មានសន្លឹកកិច្ចការរបស់សិស្ស<br>– គ្រូជួយណែនាំដល់សិស្សពេលធ្វើពិសេធន៍<br>– សិស្សម្នាក់ៗមានការងាររៀងៗខ្លួន<br>– សិស្សកំណត់បានអត្តសញ្ញាណកម្មអាស៊ីតបាស និង ស្វ៊ឺត តាមរយៈអង្គធាតុ ចង្អុលពណ៌ ក្រដាស PH ស្រកានាគ ផ្ការរំយោលតាមក្រុម |

| |
|---|
| ចំណុចកែលម្អ<br>– គួរតែមានការពិសោធន៍ 5 ឬ 6 អាចឲ្យសិស្សមិនមានការលំបាកច្រើនអាចប្រើ ពេលតិច ។<br>– ទំហំមេរៀន និងការងារហាក់មិនសមស្រប (ដោយសារប្រើពេលវែង និងសម្ភារៈច្រើនបន្តិច)<br>– កាត់បន្ថយចំនួនស្វូលុយស្យុង<br>– គ្មានប្រាប់ពីរបៀបប្រើសន្លឹកកិច្ចការ |

- គួរបណ្ដុះឥរិយាបទនៅជំហានទី 4 ថា បើប្អូនឃើញថាក្រូចឆ្មាជូរ អាចកាត់ធ្វើឲ្យ ធ្មេញពុក ដូចនេះហើយទើបគេប្រើថ្នាំដុសធ្មេញដែលជាលក្ខណៈបាស។ ដូច្នេះ ជាការប្រសើរបើគ្រូអាចបណ្ដុះគំនិតឲ្យអនុវត្តចំពោះខ្លួនសិស្ស (បំនិនជីវិតក្រោយពីការរៀនមេរៀននេះ)
- គួរបង្ហាញប្លង់ពិសោធន៍ ដើម្បីឲ្យដំណើរការសិក្សាទាន់ពេល
- គួរកំណត់ពេលវេលានៅក្នុងជំហាននីមួយៗ
- គួរប្រើសារធាតុ ឬស្លាបព្រាបុយស្យូង 4–5 មុខ បានហើយចៀសវាងចំណាយពេលច្រើន
- សូមឲ្យលោកគ្រូបង្រៀនត្រៀមលក្ខណៈជាមុនឲ្យបានសមស្របមុនពេលបង្រៀន ថាតើធ្វើសកម្មភាពបែបណាទើបបង្រៀនទាន់ម៉ោងកុំឲ្យលើសម៉ោងច្រើនពេក។
- គួរប្រើសារធាតុ 6មុខ ដើម្បីឲ្យចំណេញពេល
- គួរទុកពេលឲ្យសិស្សបកស្រាយ
- គួរប្រើអង្គធាតុចង្អុលពណ៌តែមួយ
- គួរកាត់បន្ថយចំនួនស្លាបព្រាបុយស្យូងសមស្របតាមពេលវេលា ។
- គួរបន្ថយអង្គធាតុចង្អុលពណ៌
- គួរកំណត់ពេលវេលាបង្រៀនឲ្យបានច្បាស់
- គួរពន្យល់សន្លឹកកិច្ចការឲ្យបានច្បាស់
- គួរគូសតារាងសង្កេតលទ្ធផលទុកជាមុន
- គួរយកអង្គធាតុចង្អុលពណ៌តែ 2 ដើម្បីចំណេញម៉ោង និងងាយសិស្សមានការ ចងចាំ
- គួរលើកទឹកចិត្តសិស្សពេលពួកគេបំពេញចម្លើយ

# កិច្ចតែងការបង្រៀន

ថ្នាក់ទី ៨
មុខវិជ្ជា: គីមីវិទ្យា
មេរៀនទី២: វិធីញែកល្បាយ
ចំណងជើងរង: ចម្រោះ
ប្រធានបទ: ការកំណត់ប្រភេទតម្រង
រយៈពេល: ០១ម៉ោង

**I– វត្ថុបំណង:**
- រៀបរាប់ពីការប្រើប្រាស់តម្រងក្នុងការច្រោះតាមរយៈការសង្កេត និង ច្រោះល្បាយបានត្រឹមត្រូវ ។
- កំណត់ប្រភេទតម្រងក្នុងការច្រោះតាមរយៈពិសោធន៍បានត្រឹមត្រូវ ។
- អនុវត្តវិធីចម្រោះក្នុងជីវភាពរស់នៅតាមរយៈកិច្ចការផ្ទះ ។

**II – សម្ភារបង្រៀន:**
- ឧបករណ៍ ៖ ដបទឹកបរិសុទ្ធ ឬ កែវជ័រ ស្បៃ ក្រណាត់  ក្រដាសច្រោះ ជីឡាវ
- សារធាតុគីមី ៖ គ្រួស ខ្សាច់ ដី អំបិល និង ទឹក
- ឯកសារ ៖

**III– ដំណើកនាំមេរៀន៖**

| សកម្មភាពគ្រូ | ខ្លឹមសារ | សកម្មភាពសិស្ស |
|---|---|---|
| គ្រូតពិនិត្យ អនាម័យ វិន័យ វត្តមាន | ជំហានទី១<br>រដ្ឋបាលថ្នាក់ | ប្រធានថ្នាក់រាយការណ៍ |
| ១-ចូរឲ្យនិយមន័យ<br>-ល្បាយ<br>-ល្បាយស្មើសាច់<br>-ល្បាយមិនស្មើសាច់<br>២- តើគេញែកសារធាតុបង្កល្បាយបានដែរឬទេ? | ជំហានទី២<br>រំឭកមេរៀនចាស់ | -ល្បាយ.................................<br>-ល្បាយស្មើសាច់........................<br>-ល្បាយមិនស្មើសាច់..................<br><br>- អាចញែកបាន<br>- មិនអាចញែកបាន |
| -ចែកសិស្សជាក្រុម ( ៥នាក់ ១ក្រុម)<br><br>-បង្ហាញការបង្កើតល្បាយ និង ណែនាំសិស្សឲ្យសង្កេត ។ | ជំហានទី ៣<br>មេរៀនទី២ ៖ វិធីញែកល្បាយ<br>១-ចម្រោះ<br>1/ សង្កេត<br>ការបង្កើតល្បាយ | -ចូលតាមក្រុម និង តាមដានដំណើរការបង្កើតល្បាយ យ៉ាងយកចិត្តទុកដាក់ ។<br>- រិះគិតវិធីញែកល្បាយខាងលើ |

<table>
<tr><td>-ផ្តល់ឱកាសឲ្យសិស្សគិតពីវិធីញែក ល្បាយខាងលើ ។<br>-សំយោគចម្លើយនិងប្រមូលអារម្មណ៍ សិស្សឲ្យចូលសំណួរគន្លឹះ ។</td><td></td><td></td></tr>
<tr><td colspan="3" align="center">2/ សំណួរគន្លឹះ ៖<br>តើយើងត្រូវប្រើតម្រងមានលក្ខណៈដូចម្តេចដើម្បីទទួលបានផលច្រោះល្អ?</td></tr>
<tr><td>- ផ្តល់ឪកាសឲ្យសិស្សប្រាប់ពីតម្រង ដែលខ្លួនធ្លាប់ប្រើ ។<br><br>- ណែនាំសិស្សឲ្យព្យាយាមគូសប្លង់ ពិសោធន៍ និង បញ្ជាក់បន្ថែមពី របៀប ពិសោធន៍ និង ការបំពេញ លទ្ធផល ក្នុងតារាង ។<br>- ផ្តល់ឪកាសឲ្យសិស្សប្រាប់ពីតម្រង ដែលខ្លួនធ្លាប់ប្រើ ។<br><br>ណែនាំសិស្សឲ្យសង្កេតផលច្រោះ រួចធ្វើការសន្និដ្ឋានលើសំណួរគន្លឹះ</td><td>3/ ការទស្សន៍ទាយសម្មតិកម្ម<br><br>4/ តេស្តសម្មតិកម្ម<br>ក ពិសោធន៍<br><br>ខ លទ្ធផលពិសោធន៍<br><table><tr><td></td><td></td><td></td><td></td><td></td></tr><tr><td></td><td></td><td></td><td></td><td></td></tr></table><br>តម្រងទី៤ (ក្រដាសច្រោះ) ទទួលបាន ផលច្រោះល្អ (ថ្លា) ជាងគេ ព្រោះកករដីមួយភាគធំ បានញែក ចេញពីល្បាយ ។<br><br>5/ សន្និដ្ឋាន<br>បើយើងប្រើតម្រងខុសៗគ្នានោះ យើងទទួលបាន ផលច្រោះក៏ខុសគ្នាដែរ ។</td><td>-កត់ត្រាសំណួរគន្លឹះ ចូលសន្លឹក កិច្ចការ ។<br><br>-គិតរួចផ្តល់ចម្លើយរៀងៗខ្លួន<br>-ព្យាយាមគូសប្លង់ និង ដំណើរការពិសោធន៍<br><br>-អនុវត្តការច្រោះ<br><br>-បំពេញចូលតារាង<br><br>ផ្តល់ចម្លើយសន្និដ្ឋានតាមក្រុម ។</td></tr>
<tr><td>ដើម្បីច្រោះល្បាយខាងក្រោម តើយើងត្រូវប្រើតម្រងប្រភេទណា សមស្រប ?<br>-ទឹកល្អក់<br>-ទឹកដូងមានកាក</td><td align="center">ជំហានទី ៤<br>ពង្រឹងពុទ្ធិ</td><td>ដើម្បីច្រោះល្បាយនេះគេត្រូវប្រើ តម្រង:<br>1 ......................<br>2......................</td></tr>
</table>

| | | |
|---|---|---|
| ចូរសរសេររបាយការណ៍ស្ដីពីដំណើរការច្រោះ។ | ជំហានទី ៥<br>បណ្ដាំផ្ញើ | អនុវត្តតាមការណែនាំរបស់គ្រូ |

## សន្លឹកកិច្ចការ

ការកំណត់ប្រភេទតម្រង

១/ សង្កេត: ការបង្កើត និងច្រោះល្បាយកករដី ទឹកតៃ

- តើល្បាយមួយណាញែកបាន? ព្រោះអ្វី?

  ទឹកតៃញែកបាន ព្រោះកាកតៃមានទំហំធំជាងសំនាញ់តម្រង

២/ សំណួរគន្លឹះ

| **តើយើងត្រូវប្រើតម្រងមានលក្ខណៈដូចម្តេចដើម្បីទទួលបានលទ្ធផលល្អ?** |
|---|

៣/ ការទស្សន៍ទាយសម្មតិកម្ម

ដើម្បីញែកកករដីយើងប្រើតម្រង:

- ស្បៃ
- ក្រណាត់សារ៉ូ
- ក្រណាត់តេតារ៉ុង
- ក្រដាសច្រោះ

៤/ សម្មតិកម្ម

- ពិសោធ

- លទ្ធផលពិសោធ

| តម្រង | ស្បៃ | សារ៉ូ | តេតារ៉ុង | ក្រដាស |
|---|---|---|---|---|
| ផលច្រោះ | ទឹកល្អក់ | ទឹកល្អក់ | ទឹកល្អក់ | ទឹកថ្លា |

- តើតម្រងណាទទួលបានផលច្រោះល្អ(ទឹកថ្លា) ជាងគេ? ព្រោះអ្វី?

  តម្រងក្រដាស ព្រោះកករដីមួយភាគធំទើលើតម្រង។

៥/ សន្និដ្ឋាន

ដើម្បីទទួលបានផលច្រោះល្អ យើងត្រូវតម្រងមានក្រលាសំណាញ់តូចជាងភាគល្អិតអង្គធាតុរឹង។

# យោបល់ និងសំណូមពរ

ចំណុចល្អ
- ឲ្យសិស្សលើកមកបង្ហាញនូវល្បាយ និងឧបករណ៍សុទ្ធតែទាក់ទងនិងជីវភាព ប្រចាំថ្ងៃ ។
- ទាញសម្មតិកម្មទៅនិងផលច្រោះក្នុងពិសោធន៍ចប់របស់សិស្ស ។
- ផ្ទៀងផ្ទាត់លទ្ធផលពិសោធន៍ទៅនឹងសម្មតិកម្ម
- ផ្តល់ឱកាសឲ្យសិស្សជ្រើសរើសឡើងបង្ហាញ
- គ្រូបង្កើតសម្មតិកម្មឲ្យសិស្សរិះរក
- គ្រប់ជំហានទាំង 5
- ពន្យល់សិស្សបានច្បាស់លាស់
- គ្រូផ្តល់ឱកាសឲ្យរកវិធី រកប្រភេទតម្រងផ្សេងមកចម្រោះ
- ការបង្ហាញបាតុភូមិបានល្អ
- សិស្សមានការចង់ដឹងសួរសំនួរដែលខ្លួនឆ្ងល់ទៅគ្រូ
- មានសេចក្តីសន្និដ្ឋានច្បាស់លាស់
- សិស្សសកម្មក្នុងការធ្វើពិសោធន៍
- មានរំលឹកមេរៀនចាស់
- មានសំនួរល្អៗ
- លទ្ធផលបានរកឃើញ
- រកហេតុផលនៃតម្រង
- អ្នកគ្រូមានសម្ភារៈឧបទ្ទេសច្រើនមកបង្ហាញសិស្សទាយ
- សិស្សឆ្ងល់ការគ្រឹតលើកែវ
- ស្មានតែឲ្យប្រើសំឡីមកធ្វើការច្រោះក៏បានលទ្ធផលទឹកថ្លា ដូចក្រដាសដែរ ។
- បណ្តុះការគិតរបស់សិស្ស
- ឲ្យសិស្សធ្វើសេចក្តសន្និដ្ឋានដោយខ្លួនឯង និងក្រុមបន្ទាប់ សរសេរលើក្តារខៀន
- មានលំនាំបង្រៀនវិទ្យាស្ត្រខ្លះៗ (ផ្សារភ្ជាប់នឹងជីវភាពរស់នៅ)
- តាមដានសិស្សពេលពិសោធន៍ និងឲ្យបំពេញតារាងកិច្ចការ
- សិស្សចេះកំណត់បញ្ហា
- ឲ្យសិស្សធ្វើសកម្មភាពពិសោធន៍ដោយខ្លួនឯង
- រកឧទាហរណ៍ឲ្យសិស្សងាយយល់
- ចេះប្រៀបធៀបពីតម្រងមួយទៅតម្រងមួយ
- ញែកល្បាយឲ្យបានច្បាស់លាស់
- មានប្លង់ពិសោធន៍
- សិស្សឆ្លើយបានច្រើន និងគំនិតយោបល់ផ្សេងៗគ្នា
- សិស្សសកម្ម
- ឲ្យសិស្សរកពីវិធីញែកកាហ្វេ និងតែ
- សិស្សគូរប្លង់ពិសោធន៍តាមគ្រូដែលបិទនៅលើក្តារខៀន
- ឲ្យសិស្សតាមក្រុមបង្ហាញពីហេតុផលដែលទទួលបានក្រោយពេលពិសោធន៍

ចំណុចកែលម្អ

- គួរតែបង្ហាញពីប្រភេទល្បាយដែលត្រូវយកមកពិសោធន៍ ដើម្បីឲ្យសិស្សឃើញ ដើម្បីឲ្យសិស្សគិតថាតើត្រូវប្រើតម្រងណាមួយក្នុងការចម្រោះយកអង្គធាតុ ល្បាយ ។
- គួរតែបង្ហាញដំណើរពិសោធន៍ដើម្បីទទួលបានផលច្រោះតាមអង្គធាតុនិមួយៗ ទៅនិងប្រភេទតម្រង ។ ថាតើតម្រងមួយណាទទួលបានអង្គធាតុអ្វីវិញ ។
- គួរឲ្យសិស្សដាក់ចំណងជើងមេរៀន និងវិធីញែកល្បាយ
- គួរឲ្យសិស្សធ្វើពិសោធន៍តាមសម្មតិកម្ម និងដំណើរការពិសោធន៍របស់គេ
- គួរឲ្យសិស្សម្នាក់ដែលប្រើសំលីច្រោះ ឡើងបង្ហាញនិងពន្យល់ពីរបៀបច្រោះរបស់ គាត់ដោយប្រើសំលី ដើម្បីសំយោគជាមួយក្រដាសតម្រង ។
- ចង់ឲ្យគាត់កាត់បន្ថយការនិយាយនិងសួរសំនួរខ្លះ
- គួរបិទសេចក្តីសន្និដ្ឋានចុងក្រោយរបស់គ្រូ ដើម្បីឲ្យសិស្សផ្ទៀងផ្ទាត់សម្មតិកម្ម របស់ខ្លួនថាត្រូវឬខុស ។
- គួរតែណែនាំសិស្សមានការប្រុងប្រយ័ត្នក្នុងការប្រើប្រាស់សម្ភារៈពិសោធន៍ នៅពេលពិសោធន៍
- គួរតែណែនាំសិស្សបានច្បាស់នៅក្នុងល្បាយមានសារធាតុអ្វីខ្លះ?
- គួរតែកំណត់បរិមាណល្បាយក្នុងកែវ
- គួរទុកពេលសិស្សធ្វើពិសោធន៍វែងបន្តិច 15នាទី
- គួរចាបើអារម្មណ៍លើជំហានវិទ្យាសាស្ត្រនីមួយៗ
- គួររៀបរាប់ពីដំណើរការពិសោធន៍ឲ្យបានលម្អិតបន្តិច
- គួរប្រើសំនួរបំផុសក្នុងសកម្មភាពនិមួយៗឲ្យចំគោលដៅ
- គួរអនុវត្តតាមលំដាប់លំដោយមេរៀនកុំច្របូកច្របល់
- គួរទុកពេលអនុវត្តពិសោធន៍ឲ្យបានច្រើនបន្តិច
- គ្រូសួរតែមានសេចក្តីសន្និដ្ឋានបិទលើក្តារខៀន
- អ្នកគ្រូត្រូវណែនាំឲ្យសិស្សធ្វើពិសោធន៍
- គួរកុំប្រើអ្វីដែលទាក់ទងប្រតិកម្ម
- សិស្សរៀបចំប្លង់ពិសោធន៍មិនទាន់បានត្រឹមត្រូវ
- គ្រូគួរផ្តល់តម្រុយខ្លះនៅពេលដើរ
- ក្នុងសម្ភារៈបង្រៀនមានសម្ភារៈមួយចំនួនមិនមានដាក់ក្នុងកិច្ចតែងការបង្រៀន
- គួរបន្ថយការសង្ខេបលើសម្មតិកម្មទុកសម្រាប់ធ្វើវាយតម្លៃវិញ
- គួរបង្ហាញសំនួរគន្លឹះតែម្តង ព្រោះបើទុកពេលឲ្យសិស្សគិតត្រូវចំណាយពេលយូរពេក
- បើខ្ញុំធ្វើវិញ គឺមិនដាក់អំបិលចូលទេ ព្រោះអំបិលមិនអាចច្រោះបានទេ តែខ្ញុំទុកធ្វើលើតែ និងកាហ្វេវិញ ដើម្បីបញ្ជាក់ពីការដែលមិនអាចញែកពណ៌ដោយប្រើ តម្រង
- បង្ហាញឲ្យកាន់ឥតច្បាស់ជាងនេះទៀត

# កិច្ចតែងការបង្រៀន

ថ្នាក់ទី១០

មុខវិជ្ជា ជីវវិទ្យា

ជំពូកទី៥

មេរៀនទី៣ ដើម និង ស្លឹក

ចំណុចដែលត្រូវបង្រៀនៈ ការងារអនុវត្តន៍ បរិមាណស្តូម៉ាត (ទំព័រ១៨៩)

រយៈពេលបង្រៀន ៦០នាទី

I– វត្ថុបំណង

- បកស្រាយភាពខុសគ្នានៃបរិមាណស្តូម៉ាតនៅផ្នែកខាងលើស្លឹក និងផ្នែកខាងក្រោមស្លឹក តាមរយៈការពិសោធបានច្បាស់លាស់
- ជំនាញបកយកកោសិកាស្តូម៉ាតពីស្លឹកតាមរយៈការងារជាក្រុមបានត្រឹមត្រូវ
- ស្រឡាញ់ការដាំដើមឈើ និងអត្ថប្រយោជន៍របស់វាចំពោះបរិស្ថាន។

II– សម្ភារបង្រៀន

- សៀវភៅជីវវិទ្យាថ្នាក់ទី១០ របស់ក្រសួងអប់រំយុវជន និងកីឡា បោះពុម្ព ឆ្នាំ ២០០១
- សន្លឹកកិច្ចការ ប្លង់ក្តារខៀន
- ស្លឹករុក្ខជាតិឪកូទីលេដូន ស្កុតថ្លា ឡាម ទឹកថ្នាំលាបក្រចក(ថ្លា) មីក្រូទស្សន៍

III–ដំណើរការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| . ត្រួតពិនិត្យវត្តមាន<br>. ត្រួតពិនិត្យសណ្តាប់ធ្នាប់<br>. ប្រមូលអារម្មណ៍សិស្ស | <u>ជំហានទី១</u> រដ្ឋបាលថ្នាក់(៣នាទី)<br>. ត្រួតពិនិត្យវត្តមាន<br>. ត្រួតពិនិត្យសណ្តាប់ធ្នាប់ | . កិច្ចស្វាគមន៍ |
| . តើរុក្ខជាតិមានដំណកដង្ហើមដែរឬទេ?<br>. ចំពោះសារពាង្គការរុក្ខជាតិ តើឧស្ម័នចេញ និងចូលតាមរយៈអ្វី?<br>. តើស្តូម៉ាតនៅផ្នែកណានៃរុក្ខជាតិ? | <u>ជំហានទី២</u> រំលឹកមេរៀន(៧នាទី)<br>រុក្ខជាតិមានដំណកដង្ហើមតាមរយៈស្តូម៉ាតដោយស្រូបយកឧស្ម័នអុកស៊ីសែន ហើយបញ្ចេញឧស្ម័នកាបូនិច។ | . មាន<br>. តាមស្តូម៉ាត<br>. នៅនឹងស្លឹករបស់រុក្ខជាតិ |

<table>
<tr>
<td></td>
<td><u>ជំហានទី៣</u> ការងារអនុវត្តន៍<br>(៤០នាទី)<br><u>ស្តូម៉ាតរបស់រុក្ខជាតិ</u><br>ការកំណត់បញ្ហា</td>
<td></td>
</tr>
<tr>
<td colspan="3">ចូរសង្កេតមើលបរិមាណស្តូម៉ាតនៅផ្នែកខាងលើ និងផ្នែកខាងក្រោមស្លឹក របស់រុក្ខជាតិឪកូទីលេដូន។</td>
</tr>
<tr>
<td>សម្មតិកម្ម<br>. អោយសិស្សផ្តល់ចម្លើយ<br><br>ចែកក្រុមសិស្សជា៦ក្រុម<br>អោយសិស្សរៀបចំប្លង់ពិសោធតាមក្រុម<br>. អោយ ២ ឬ៣ក្រុមឡើងរាយការណ៍ពីដំណើរការរបស់ពួកគេ ៤ ក្រុមដទៃទៀតបន្ថែម<br>. ចែកសន្លឹកកិច្ចការ<br>. ពន្យល់ពីរបៀបធ្វើ<br></td>
<td>ការបង្កើតសម្មតិកម្ម<br>នៅផ្នែកផ្ទៃខាងលើស្លឹកមានចំនួនស្តូម៉ាតតិចជាង ផ្ទៃខាងក្រោមស្លឹក។<br>ពិសោធន៍<br>ចែកក្រុមពិភាក្សា<br><br>. រៀបចំប្លង់ពិសោធន៍<br><br>. ពិសោធន៍តាមសន្លឹកកិច្ចការ<br>. ណែនាំពីរបៀបវាស់ និងបិតភ្ជាប់ទៅនឹងស្លឹក<br> <br>លទ្ធផល<br><table><tr><td>ផ្ទៃលើស្លឹក</td><td>ផ្ទៃក្រោមស្លឹក</td></tr><tr><td>ស្តូម៉ាតមាន ចំនួនតិច</td><td>ស្តូម៉ាតមាន ចំនួនច្រើន</td></tr></table></td>
<td>សម្មតិកម្ម<br>នៅផ្នែកផ្ទៃខាងលើស្លឹកមានចំនួនស្តូម៉ាតតិចជាង ផ្ទៃខាងក្រោមស្លឹក។<br><br>. សិស្សអនុវត្តន៍<br><br>លទ្ធផល<br><table><tr><td>ផ្ទៃលើស្លឹក</td><td>ផ្ទៃក្រោមស្លឹក</td></tr><tr><td>ស្តូម៉ាតមាន ចំនួនតិច</td><td>ស្តូម៉ាតមាន ចំនួនច្រើន</td></tr></table></td>
</tr>
</table>

| ***បូកសរុបចម្លើយ*** | ***វិភាគទិន្នន័យ*** | ***សិស្សបកស្រាយ*** |
|---|---|---|
| . អោយសិស្សសន្និដ្ឋាន | **សន្និដ្ឋាន**<br>ដូច្នេះ រុក្ខជាតិឌីកូទីលេដូនភាគច្រើនមានចំនួនស្តូម៉ាត នៅផ្ទៃខាងក្រោមស្លឹកច្រើនជាង ផ្ទៃខាងលើស្លឹក។ | **សន្និដ្ឋាន**<br>ដូច្នេះ រុក្ខជាតិឌីកូទីលេដូនភាគច្រើនមានចំនួនស្តូម៉ាត នៅផ្ទៃខាងក្រោមស្លឹកច្រើនជាង ផ្ទៃខាងលើស្លឹក។ |
| . បិទរូបភាពអោយសិស្សទស្សន៍ទាយ | <u>ជំហានទី៤</u> ពង្រឹងពុទ្ធិ(៧នាទី)<br> | |
